BMI0156

# សម្ភាសន៍ជាមួយឈ្មោះ មុន មុត ភេទប្រុស អាយុ៥៤ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ “ប្រធានកងធំ”
## រស់នៅភូមិស្រែះ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## សម្ភាសន៍ថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ឡុង ដានី
## ០១:៥៦:០៧
## ៥៧ទំព័រ

ដានីៈ អញ្ចឹងខ្ញុំចង់ស្គាល់ឈ្មោះពេញរបស់លោកពូ តើលោកពូឈ្មោះអីដែរ?

មុតៈ ខ្ញុំឈ្មោះមុន មុត ។

ដានីៈ អាហ្នឹងឈ្មោះដើម?

មុតៈ បាទ! ឈ្មោះដើម កាលសម័យប៉ុល ពត ក៏ឈ្មោះហ្នឹងដែរ តែដល់ក្រោយមកទៅរៀននៅស្រុកគេខ្ញុំដាក់ឈ្មោះ មុន សារឿន ។

ដានីៈ ហៅ មុន សារឿន?

មុតៈ បាទ!

ដានីៈ ពូអត់មានឈ្មោះអីទៀតទេ?

មុតៈ អត់មានទេ មានតែប៉ុណ្ណឹងឯង ។

ដានីៈ មានតែប៉ុណ្ណឹងទេ?

មុតៈ បាទ!

ដានីៈ ឈ្មោះពីកំណើតឈ្មោះ មុន មុត ដល់ពេលឈ្មោះ មុន សារឿន នេះ?

មុតៈ ឈ្មោះក្រោយ ។

ដានីៈ ក្រោយឆ្នាំណា?

មុតៈ ក្រោយឆ្នាំបែកពីប៉ុល ពត ទៅ ។

ដានីៈ អ៊ំ! ក្រោយពីបែកប៉ុល ពត?

មុតៈ បាទ! កាលសម័យ៧៩ ។

ដានីៈ បាទ! ពូសព្វថ្ងៃអាយុប៉ុន្មានហើយ?

មុតៈ ខ្ញុំអាយុ៥៨ឆ្នាំ ។

ដានីៈ ស្រុកកំណើតកើតជារបស់ពូនៅណាដែរ?

មុតៈ នៅភូមិស្រែះខាងកើត ។

ដានីៈ ឃុំអី?

មុតៈ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

ដានីៈ សព្វថ្ងៃពូរស់នៅឯណាដែរ?

មុតៈ សព្វថ្ងៃខ្ញុំរស់នៅភូមិស្រែះខាងកើត ។

ដានីៈ ឃុំព្រះនេត្រព្រះដដែល?

មុតៈ ឃុំព្រះនេត្រព្រះដដែល ។

ដានីៈ គ្រួសាររបស់ពូគាត់ឈ្មោះអីដែរ?

មុតៈ ឈ្មោះ នោ គឹមលាង ។

ដានីៈ មីងអាយុប៉ុន្មានហើយសព្វថ្ងៃ?

មុតៈ អាយុ៤៥ឆ្នាំ ។

ដានីៈ ពូមានកូនចៅប៉ុន្មាននាក់ដែរ?

មុតៈ ខ្ញុំមានកូនចៅទាំងអស់៥នាក់ ។

ដានីៈ ស្រីប៉ុន្មាន ហើយប្រុសប៉ុន្មាន?

មុតៈ ទី១ប្រុស ទី២ស្រី ប្រុស៤ ហើយស្រី១ ។

ដានីៈ ប្រុស៤ ស្រី១ ហើយធំៗអស់ហើយ?

មុតៈ បាទ! បានប្តីបានប្រពន្ធ៣នាក់ នៅសល់២នាក់នៅលីវ ។

ដានីៈ ហើយពូឥឡូវប្រកបមុខរបររកស៊ីធ្វើអីដែរ?

មុតៈ ខ្ញុំធ្វើស្រែ ។

ដានីៈ ធ្វើស្រែហើយមានធ្វើអីទៀត?

មុតៈ អត់មានធ្វើអីទេ នៅផ្ទះមានតែលក់អីបន្តិចបន្តួចហ្នឹង ចិញ្ចឹមជ្រូក ។

ដានីៈ ពូ ឪពុករបស់ពូគាត់ឈ្មោះអី?

មុតៈ គាត់ឈ្មោះ ជួ មុន ។

ដានីៈ សព្វថ្ងៃគាត់នៅរស់ទេ?

មុតៈ គាត់ស្លាប់ឆ្នាំ៧៧ ។

ដានី៖ ចុះម្តាយ?

មុត៖ ម្តាយឈ្មោះ អោ ផែង ។

ដានី៖ គាត់នៅរស់ឬក៏?

មុត៖ គាត់ស្លាប់ហើយ ស្លាប់សម័យអ៊ុន គាក់ កាលឆ្នាំ៩១-៩២ហ្នឹង ។

ដានី៖ ពូមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

មុត៖ បងប្អូនបង្កើត៦នាក់ ។

ដានី៖ ស្រីប៉ុន្មាន ហើយប្រុសប៉ុន្មាន?

មុត៖ ស្រី២នាក់ ហើយប្រុស៤នាក់ ។

ដានី៖ ពូកូនទីប៉ុន្មានដែរ?

មុត៖ ខ្ញុំកូនទី៥ ។

ដានី៖ ពូ កាលពីក្មេងៗពូរៀនសូត្រដល់ថ្នាក់ណាដែរ?

មុត៖ ខ្ញុំរៀនថ្នាក់ទី១០ចាស់ សម័យធៀវគី ផ្នេញខ្មៅ ។

ដានី៖ សម័យវៀតកុងមែន?

មុត៖ បាទ! សម័យយៀកកុងផ្នេញខ្មៅ គេហៅយួនធៀវគីព្រៃនគរ ។

ដានី៖ អ៊ី!

មុត៖ ខ្ញុំនៅរៀនបាត់ដំបង រៀនអត់បានចប់ទេ ។

ដានី៖ រៀនថ្នាក់ទី១០នៅសាលាណា?

មុត៖ រៀននៅសាលាកៀនវត្តកំផែង សាលាអីទេ?

ដានី៖ ជិតវត្តកំផែងនៅបាត់ដំបងវិញ?

មុត៖ បាទ!

ដានី៖ ម៉េចបានជាពូទៅរៀននៅបាត់ដំបងវិញ?

មុត៖ ខ្ញុំទៅតាមបងប្អូននៅនោះ ដែលកាលភៀសខ្លួនពីស្រុកស្រែទៅនៅរៀននោះ បងខ្ញុំធ្វើគ្រូមួយ ។

ដានី៖ បងធ្វើគ្រូនៅណា?

មុត៖ ធ្វើគ្រូនៅបាត់ដំបង សព្វថ្ងៃគាត់ស្លាប់ហើយ ប៉ុល ពត សម្លាប់នៅភ្នំស្រុក គេជម្លៀសមកបាត់ដំបងនៅភ្នំស្រុក ។

ដានី៖ ពូចូលរៀននៅឆ្នាំណាហើយឈប់ឆ្នាំណាទៅ?

មុត៖ ខ្ញុំឈប់រៀននៅឆ្នាំ៧៣ ។

ដានី៖ ឈប់រៀននៅឆ្នាំ៧៣?

មុត៖ បាទ! ហើយចូលរៀនតាំងពីអាយុ៩ឆ្នាំ រៀននៅស្រុកស្រែដូចថាវាបុិលប៉ូច រវល់តែរត់ ។

ដានី៖ អញ្ចឹងទៅបាត់ដំបងតាំងពីអាយុ៩ឆ្នាំ?

មុត៖ ទេ ទៅបាត់ដំបងទើបតែថ្នាក់ទី១១ហើយ ទៅរៀននោះបានមួយឆ្នាំជាងពីរឆ្នាំ ។

ដានី៖ ហើយឆ្នាំ៧៣ឈប់រៀន?

មុត៖ បាទ!

ដានី៖ ហើយម៉េចបានឆ្នាំ៧៣ឈប់រៀន?

មុត៖ ឆ្នាំ៧៣ឈប់រៀនហ្នឹងមូលហេតុដូចថា ស្រុកស្រែវាក្តៅ ហើយវៃវាលបែកចានវៃអីដង វៃពីស្រុកហ្នឹងខ្លាំង ខ្ញុំរត់ទៅជ្រកកោននៅនោះរៀននៅនោះហ្នឹងទៅ អញ្ចឹងបានថាការរៀននោះវាគ្រឡូកគ្រលៀកទៅមកៗ ម៉ែឪហ្នឹងវាពិបាកវេទនា ។

ដានី៖ ចុះពូដល់ពេលយើងឈប់រៀនឆ្នាំ៧៣ហ្នឹង ពូទៅណាទៀត?

មុត៖ ខ្ញុំឆ្នាំ៧៣ត្រលប់មកស្រុកកំណើតវិញ ពីបាត់ដំបងមក ។

ដានី៖ ត្រលប់មកស្រុកកំណើតមកនៅជាមួយ?

មុត៖ ត្រលប់មកនៅជាមួយម៉ែឪ ជុំគ្រួសារ ជួបជុំបងប្អូនគ្រួសារនៅស្រុកនេះវិញ ។

ដានី៖ នៅជាមួយគ្រួសារធ្វើអីទៅ?

មុត៖ នៅជាមួយគ្រួសារធ្វើស្រែជាមួយម៉ែឪ នៅក្នុងបន្ទុកម៉ែឪ ធ្វើស្រែចំការដូចគាត់ដែរ គាត់អ្នកស្រែចំការ ។

ដានី៖ ពូធ្វើស្រែជាមួយឪពុកម្តាយដល់ពេលណាទៅ?

មុត៖ ដល់ពេលឆ្នាំ៧៥ គេរំដោះបានពួកយោធាខ្មែរក្រហមចូលមកនៅស្រុកនេះចាប់ផ្តើមគេឲ្យយើង ទៅជីកទំនប់លើកប្រលាយនៅគោករំចេក ។

ដានី៖ កាលហ្នឹងពូចូលកងនឹងគេនូវ?

មុត៖ ចូលកងគោករំចេក ។

ដានី៖ គេហៅកងអី?

មុត៖ គេហៅកង អត់ទាន់ថាជាចល័តជាអីទេ គ្រាន់តែគេកេងគរទៅអត់ទាន់ដាក់ឈ្មោះជាអីទេ គេទើបចូលមកដល់ គេប្រមូលទៅមួយកន្លែង លើកទំនប់គោករំចេក អូរគោករំចេកផ្លូវភ្នំស្រុក ។

ដានី៖ អញ្ចឹងកាលហ្នឹងលើកទំនប់នៅអូរគោករំចេក?

មុត៖ ក្រោយមកទៀត ។

ដានី: កាលហ្នឹងកងរបស់ពួកហ្នឹងដូចថា សុទ្ធតែក្មេងៗប៉ុក៏មានចាស់ៗដែរ?

មុត: មានៗ

ដានី: លាយគ្នា?

មុត: លាយគ្នាគ្រប់ស្រុកគ្រប់ភូមិទាំងអស់ គេដឹកដើមចេកដើមល្ហុងយកទៅឲ្យស៊ីៗ

ដានី: កាលហ្នឹងមានច្រើនទេ?

មុត: ដំបូងបងប្អូនថ្មីគាត់មិនទាន់មកចេញពីភ្នំពេញមកខ្លះផង គាត់ចូលមកព្រឹកមុនដំបូងគេកៀរតាមស្រុកតាមអីឲ្យទៅលើកទំនប់មុនដំបូង អានោះកងមុនដំបូង កងកន្ទែងគោករំចេកខ្លាំងដែរៗ

ដានី: គ្នាប៉ុន្មាននាក់ទៅមុនដំបូងហ្នឹង?

មុត: ច្រើន គ្រប់ភូមិ គ្រប់ឃុំ គ្រប់សង្កាត់ទាំងអស់កៀនម៉ាស្រុកព្រះនេត្រព្រះ ម៉ាខេត្តបន្ទាយមានជ័យនេះ មិនដឹងមកពីខាងណាខាងណីទេៗ

ដានី: ប្រហែលជារយប៉ុក៏ពាន់?

មុត: ប្រហែលពាន់នាក់ ម៉ឺននាក់ កាលហ្នឹងនៅស្បៀងអាហារស៊ីធម្មតា រាប់ម៉ឺនៗ

ដានី: កាលហ្នឹងប្រធានគេឈ្មោះអីទៅ កាលលើកទំនប់នៅគោករំចេក?

មុត: ប្រធានគោករំចេកឈ្មោះតា លឿម ក្រោយមកទៀតគេផ្លាស់ប្តូរ កាលជួបមុនដំបូងឈ្មោះតា លឿមៗ

ដានី: តា លឿមៗ

មុត: មិនហ៊ាននិយាយហ្នឹងគេផង ឃើញគេមួយភ្លែតៗថាគេក្តាប់ធំៗ

ដានី: តាលឿម ហ្នឹងគាត់ប្រធានអី?

មុត: ប្រធានក្តាប់ពួកអ្នកលើកទំនប់អ្នកអីហ្នឹង តែមិនដឹងថាស្អីទេៗ

ដានី: គេហៅថាប្រធានកងចល័ត ប៉ុក៏ប្រធាន?

មុត: អត់ទាន់ចេញជាចល័តទេ តាវ៉ាល់ ស្រួល គាត់ដាក់ងារថាជាចល័តតំបន់ ហើយគាត់ជាប្រធានចល័តតំបន់ ហើយ តាលឿម ហ្នឹងដូចជាឃុំតែមិនទាន់តែងតាំងជាស្អីទេ គាត់ចូលពីព្រៃមកថ្មីៗ អាហ្នឹងទី១ ៗ

ដានី: គាត់គ្រាន់តែប្រធានកន្ទែងហ្នឹង?

មុត: គាត់ក្តាប់រួម ដោះស្រាយស្អីៗហ្នឹង មិនដឹងជាប្រធានការដ្ឋាន យើងថាប្រធានការដ្ឋានទៅៗ

ដានី: ប្រធានការដ្ឋាន?

មុត: បាទ! គាត់ដោះស្រាយស្បៀងអាហារ ប្រហុកអំបិលអីៗ

ដានី: តាលឿម គាត់អ្នកស្រុកណាដែរ?

មុត: ខ្ញុំអត់ស្គាល់គេទេ គេអ្នករំដោះ ។

ដានី: អញ្ចឹងយើងពេលដែលបែក៧៥មកភ្នាម ពូចាប់ផ្ដើមជ្រើសរើសឲ្យចូលកងហ្នឹង?

មុត: បាទ! ចាប់ផ្ដើមពីទំនប់គោករំចេកមក ហើយបានចងក្រងគេបង្កើតឲ្យខ្ញុំទៅតាមមុខព្រួញតាវ៉ាល់ តែម្ដង ។

ដានី: មុនហ្នឹងបន្តិច លោកពូពេលដែល៧៥ដំបូង កាលហ្នឹងយើងចូលកងហ្នឹងយើងស្ម័គ្រចិត្តចូលឬក៏គេជ្រើសរើសឬក៏បង្ខំឲ្យយើងចូល?

មុត: កាលនោះគេប្រមូលទៅ ដូចថាវ៉ារប៉ាត់រប៉ាយតាំងពីគោករំចេក ពេលណាចប់ហើយដូចថាគ្មានទិសដៅថាឲ្យមកផ្ទះសម្បែងទេ ពេលហ្នឹងចល័ត តាវ៉ាល់ គេយកទៅដាក់ជាការដ្ឋានមួយទៅគេរៀបចំធ្វើជាកងចល័តទៅ ពិបាកថាស្ម័គ្រចូល ។

ដានី: អញ្ចឹងកាលទៅគោករំចេកដំបូងក៏អត់ស្ម័គ្រដែរ?

មុត: អត់ស្ម័គ្រទេ គេកែនយើងទៅតែម្ដង គេឲ្យយើងទៅ ។

ដានី: គេកែនទៅហ្នឹង?

មុត: បាទ! ខ្ញុំតូចហ្នឹង ។

ដានី: កាលហ្នឹងពូអាយុប៉ុន្មាន?

មុត: កាលហ្នឹងខ្ញុំអាយុ១៧-១៨ហ្នឹង ។

ដានី: អញ្ចឹងអ្នកដែលទៅលើកទំនប់ហ្នឹង អាយុប្រហែលជាចន្លោះប៉ុន្មានទៅប៉ុន្មាន?

មុត: ច្រើនណាស់ វ៉ាមានវ័យ៦០ មាន២០ មាន៣០ មាន៤០ខ្លះទៅ ។

ដានី: រាប់រយនាក់?

មុត: រាប់រយនាក់ ។

ដានី: ចុះពូកាលហ្នឹងពូទៅលើកទំនប់នៅអូរគោករំចេកហ្នឹងរយៈពេលប៉ុន្មានទៅ?

មុត: អូរគោករំចេកប្រហែលជារយៈពេល៤ខែ ចប់ទំនប់គោករំចេកមក មកកាន់ជប់វ៉ារីវិញ ចប់ផែនការទី១ គេយកមកលេងសិល្បៈនៅវត្តគោកថាយនៅជប់ឲ្យមើល ទទួលបាយទទួលទឹកដែរលេងកុនលេងអីសំពត់សធំឲ្យមើល ។

ដានី: អញ្ចឹងដល់ពេលលើកនៅហ្នឹង៤ខែ បានត្រលប់មកជប់វ៉ារី?

មុត: បាទ! ដូចថាយើងចប់ពីកិច្ចការមកគេប្រមូលយើងឡើងមកជប់លៀង ហើយគេចាប់ផ្ដើមរើសជាយោធា ។

ដានី៖ ចាប់ផ្ដើមរើសជាយោធា?

មុត៖ រើសយោធាស្រុក អ្នកណាដែលត្រូវទៅយោធាមួយផ្នែកទៅ ធ្វើប្រវត្តិរូបបានគេយកទៅយោធាទៅ ប្រាកដជាយោធាស្រុកព្រះនេត្រព្រះហ្នឹង។

ដានី៖ ជ្រើសរើសយោធាមួយផ្នែក ហើយមួយផ្នែកទៀតស្អីទៅ?

មុត៖ ជួនណាគេរើសទៅជាពេទ្យមួយផ្នែកទៅ នៅហ្នឹងគេចំរាញ់ណា៎ ខ្ញុំឮគេនិយាយថាគេចំរាញ់យកខាងដើម ភាសាគេ។

ដានី៖ គេចំរាញ់ទៅយោធា ទៅពេទ្យ?

មុត៖ អ្នកសុខភាពល្អគេចំរាញ់ទៅពេទ្យ។

ដានី៖ ហើយមានផ្នែកអីទៀត យេធា ពេទ្យ ហើយ?

មុត៖ ដល់ក្រោយមកទៀតសេសសល់ទាំងប៉ុន្មានគេយកខ្ញុំមកដាក់នៅហ្នឹងការដ្ឋាននៅជប់ គេហៅថាកសិដ្ឋាន តាដែលក្ដាប់កសិដ្ឋានឈ្មោះ តាឆាង កសិដ្ឋានស្រុក ទន្ទឹមហ្នឹងពាណិជ្ជហ្នឹងឯង។

ដានី៖ កសិដ្ឋានស្រុក?

មុត៖ បាទ!

ដានី៖ កាលហ្នឹងពូចូលក្នុងកសិដ្ឋានណា?

មុត៖ បាទ! ចូលក្នុងកសិដ្ឋាន។

ដានី៖ ប្រធានឈ្មោះអី?

មុត៖ ឈ្មោះ ឆាង។

ដានី៖ កាលហ្នឹងអ្នកដែលជ្រើសរើសយកធ្វើយោធាមានលក្ខណៈសម្បត្តិយ៉ាងម៉េច ហើយធ្វើពេទ្យមាន លក្ខណៈសម្បត្តិយ៉ាងម៉េច ហើយការដ្ឋានមានលក្ខណៈសម្បត្តិយ៉ាងម៉េច?

មុត៖ ដែលគេជ្រើសរើសតាមដែលខ្ញុំឃើញគេធ្វើ គេសួរពីជីវប្រវត្តិយើង រឿងឋានៈ កម្មករកសិករដែលគេយកធ្វើណា៎ ឬអ្នកដែលគ្មានយុទ្ធនាការបងប្អូន អ្នកដែលថាមានជាប់ទិន្នាការគេឲ្យទៅផ្សេងទៅ មួយកន្លែងមានពីរបីយ៉ាង វណ្ណៈកសិករ វណ្ណៈកម្មករ កម្មករកសិករហ្នឹង ធ្វើស្រែចំការហ្នឹងទៅផ្សេង ហើយពួកខ្ញុំក៏ជាប់ដែរព្រោះយើងត្រង់ដែរ ធ្វើស្រែមែន។

ដានី៖ អញ្ចឹងអ្នកធ្វើយោធា គេមានវណ្ណៈគេល្អ?

មុត៖ បាទ! គេមានវណ្ណៈគេល្អ។

ដានី៖ ចុះធ្វើពេទ្យ?

មុតៈ ពេទ្យក៏គេរើសប្រវត្តិរូបដូចយោធាដែរ តែនៅកសិដ្ឋានដូចខ្ញុំមិនដឹងថែដន្យអី ពេលនោះគេរើសបំបែកទៅបាននៅស្រួលដែរ ទៅនៅកន្ទែងជាមួយលោក ឆាង ដែលក្តាប់រួម ហើយគាត់ក្តាប់ទាំងពាណិជ្ជផងនោះ ខ្ញុំធ្វើជានារសាររបស់គេ ។

ដានីៈ ពាណិជ្ជស្រុកមែន?

មុតៈ បាទ! ពាណិជ្ជស្រុក ។

ដានីៈ កាលហ្នឹងឆ្នាំណាបានគេជ្រើសរើស?

មុតៈ ឆ្នាំ៧៥-៧៦ កំពុងពេញ៧៦ ខ្ញុំបានទៅនៅកន្ទែងនោះឆ្នាំ៧៦ ។

ដានីៈ ឆ្នាំ៧៦ហ្នឹងពូចាំខែទេ ដើមខែឬក៏ចុងខែ?

មុតៈ ពេលដែលខ្ញុំបានទៅនៅជាមួយ តាឆាង ហ្នឹងឆ្នាំ៧៦ ប្រហែលជាដើមខែមិនមែនចុងទេ ព្រោះវាអាឆ្នាំ៧៥ហ្នឹងវាបានហើយ ចាប់ទៅនៅ៧៥ហ្នឹងវាចូលមកដល់ដើមខែហ្នឹងយើងនៅហើយដើមខែ៧៦ ។

ដានីៈ បាទ! ដើមខែ៧៦?

មុតៈ បាទ! បានរៀបចំតែងតាំងមានពាណិជ្ជមានអី ។

ដានីៈ កាលហ្នឹងពូចូលជានិរសា?

មុតៈ ដែលគេយកខ្ញុំទៅឲ្យនៅគេឲ្យខ្ញុំដើរតាមគេទៅ កាន់កាំភ្លើងដើរតាមគេដែរ តាមលោក ឆាង ។

ដានីៈ កាលនិរសារតា ឆាង ហ្នឹងយើងមានគ្នាប៉ុន្មាននាក់?

មុតៈ មានតា ឆាង មានគ្នា៤នាក់ ។

ដានីៈ ឈ្មោះអីខ្លះទៅពូ?

មុតៈ ឈ្មោះ ថេត នៅភ្នំលាភ១ ឈ្មោះ ថៃ នៅព្រះនេត្រព្រះ១ ឈ្មោះ ចាំ ដែលនៅជាមួយខ្ញុំនៅជាមួយលោក ឆាង ឈ្មោះ ហុង ១នៅកំពត ឈ្មោះ ឈុំ មួយនៅណាទេ តែសព្វថ្ងៃនៅស្វាយចេក ៤-៥នាក់ ម៉ាជំនាន់ហ្នឹង ហើយលោក ហុង លោក ឈុំ ហ្នឹងប្រធានខ្ញុំកាលដែល ក្តាប់ណ៎ ក្តាប់ខ្ញុំបន្តទៀត អ្នកកាន់កាំភ្លើង៤-៥នាក់ ។

ដានីៈ ចុះពូ កាលធ្វើនិរសារហ្នឹងយើងធ្វើអីខ្លះទៅ?

មុតៈ នារសារអត់មានធ្វើអីទេ ដូចថាគាត់ដើរទៅណាយើងដើរទៅហ្នឹង ដូចថាដើរអេសឈ្លក់គេណ៎ ហើយ យើងជួយស្ទូងស្រូវបងប្អូនតាមកៀនៗថ្នល់ផង ។

ដានីៈ គាត់ទៅណាយើងទៅជាមួយគាត់ដែរ?

មុតៈ បាទ! ដើរទៅជាមួយគាត់ ។

ដានី៖ ហើយធ្វើស្រែទៀត?

មុត៖ ធ្វើស្រែ ។

ដានី៖ អញ្ចឹងធ្វើតែប៉ុណ្ណឹងទេកាលធ្វើនិរសារ?

មុត៖ បាទ! អត់មានធ្វើអីផ្សេងទៀតទេ ។

ដានី៖ អញ្ចឹងមិនសូវជាពិបាកទេកាលធ្វើនិរសារ?

មុត៖ បាទ! វាពិបាកដែរ អត់មានពេលទំនេរទេ វាយ៉ាប់ដែរព្រោះយើងនៅក្នុងយើងខ្លាចគេដែរ ព្រោះគេយកយើងមក យើងមានបានមកពីព្រៃហ្នឹងគេណា៎ យើងនៅដូចថាគេឃើញយើងយ៉ាង ណាយ៉ាងណី អញ្ចឹងដឹងតែគេយកយើងទៅតាមដានកន្លែងគេ ដឹងក្រោយគេឃើញយើងថា ស្អាត ហើយយ៉ាងណាគេឃើញយើងក្មេងផងក៏មិនដឹង ហើយយើងបាននៅស្រួលយើងថា ស្រួល តែមិនដឹងថាគេយកយើងទៅតាមដានដោយវិធីណា មិនស្មានថាគេតានដានផង ព្រោះ នឹកឃើញថាគេស្រលាញ់យើងបានគេឲ្យកាន់កាំភ្លើង ខ្ញុំនឹកឃើញអញ្ចឹង ប្រហែលជាគេ ស្រលាញ់ ។

ដានី៖ ចុះពូកាលហ្នឹងនៅកន្លែងកសិដ្ឋានហ្នឹងរយៈពេលប៉ុន្មានទៅ កាលធ្វើនិរសារហ្នឹង?

មុត៖ យូ ដល់ឆ្នាំ៧៧ ។

ដានី៖ ពី៧៦ដល់៧៧?

មុត៖ ៧៧បានបែកបាក់គ្នា ។

ដានី៖ ឆ្នាំ៧៧ហ្នឹងបែកបាក់យ៉ាងម៉េច?

មុត៖ បែកបាក់ដូចថាគេរំសាយ ។

ដានី៖ រំសាយការដ្ឋានចោល?

មុត៖ ដូចថាស្ថានការវាចាប់ផ្តើមអាប់អួរហើយ ដល់ហើយវាមានចាប់អ្នកនេះចាប់អ្នកនោះ ដូចថា រំសាយអាការដ្ឋាននោះដូចថាវាវាងរបិករបក់ ខ្ញុំនេះទៅនៅកន្លែងកងចល័ត ។

ដានី៖ រំសាយការដ្ឋានហ្នឹងគេចាប់?

មុត៖ គេចាប់ ខ្ញុំគេចាប់ទៅឡើងមើលទៅ គេយកខ្ញុំពីកន្លែងកសិដ្ឋានទៅកាន់ក្តាប់រូម ចល័តតំបន់ តាវ៉ាល់ ហ្នឹងឯង ។

ដានី៖ អញ្ចឹងកាលហ្នឹងគេរំសាយការដ្ឋាន ហើយតា ឆាង ប្រធានហ្នឹងគេចាប់?

មុតៈ	តាឆាន់ គេចាប់ ហើយខ្ញុំនេះមិនដឹងថាឡេះឡូះណាបាន តាវ៉ាល់ នេះត្រូវចូលទៅកាន់ពួកចល័ត តំបន់នេះឯង សុទ្ធតែដកចេញពីពិភពមុខសញ្ញាយកទៅកាន់ ។

ដានី:	អញ្ចឹងពូយ៉ាងម៉េចបានជាពូទៅកន្លែងកងចល័ត តាវ៉ាល់?

មុតៈ	ខ្ញុំមិនដឹងយ៉ាងណា ដល់ពេលទៅគេដូចជាមិនមានផែនការទេ គេតម្រូវឲ្យទៅកន្លែងហ្នឹង ។

ដានី:	គេជ្រើសរើសឲ្យទៅ?

មុតៈ	គេជ្រើសរើសឲ្យទៅ ហើយខ្ញុំមានឈ្មោះជាមេកងក្តាប់រួមពួកនៅនោះហ្នង អត់មានទៅធ្វើអីទេ ដូចថាយកខ្ញុំពីកន្លែងហ្នឹងទៅកាន់ចល័តហ្នឹងហ្នង ។

ដានី:	ឆ្នាំណាពូ ៧៧?

មុតៈ	ឆ្នាំ៧៧ ។

ដានី:	ខែណាដែរ?

មុតៈ	ដំណើរខែច្រូត ប្រហែលជាខែប្រាំង ព្រោះស្រូវទុំដែរ ហើយបានគេចាប់ផ្តើមលើកទំនប់ ខែច្រូតហើយប្រហែលជាខែកត្តិក ។

ដានី:	ខែកត្តិក?

មុតៈ	បាទ!

ដានី:	ខែកត្តិកមានតែដើមឆ្នាំ?

មុតៈ	ដើមឆ្នាំ ។

ដានី:	ដើម៧៧?

មុតៈ	បាទ! ដើម៧៧ វាដាច់ពីឆ្នាំ៧៦ វាកៀកៗគ្នាហ្នឹងឯង ប្រហែលជាដើមហើយព្រោះខែកត្តិក ពួកយើងលើកទំនប់ ។

ដានី:	បើមិនដើមឆ្នាំ៧៧ទេ ចុង៧៦?

មុតៈ	បាទ! តែអាចខែ១១-១២ទេ?

ដានី:	តែអាចខែ១១-១២ទេ?

មុតៈ	ខ្ញុំមិនហ៊ានសន្និដ្ឋានទេ ព្រោះវានៅក្នុង គ្រាន់ថាយើងចាំទៅលើទ្រង់ទ្រាយ ។

ដានី:	ពូកាលជ្រើសរើសទៅកងចល័តរបស់ តាវ៉ាល់?

មុតៈ	បាទ!

ដានី:	តែគេហៅកងចល័តរបស់អីគេអាហ្នឹង?

មុតៈ	កងចល័តតំបន់ មេតំបន់គឺ តាហឹង កងចល័ត ។

ដានី: កងចល័តតំបន់ តំបន់ប៉ុន្មាន?

មុត: តំបន់៥ ។

ដានី: តាហឹង គាត់គណៈតំបន់?

មុត: បាទ!

ដានី: ហើយ តាវ៉ាល់ ហ្នឹងគាត់ប្រធានចល័តតំបន់?

មុត: បាទ! តាវ៉ាល់ ប្រធានចល័តតំបន់ ហើយ តាហឹង ប្រធានតំបន់៥ហ្នឹង គាត់ក្ដាប់រួមទាំង តាវ៉ាល់ តាជៀល ត្រូវយកខវ៉ាទពី តាហឹង ហ្នឹងឯង ។

ដានី: ចុះក្រោម តាហឹង មានពីណាទៀត?

មុត: ក្រុម តាហឹង កូនចៅគាត់មាន តាជៀល តាជៀល ហ្នឹងកូន តាញឹម គណៈភូមិភាគ សុទ្ធតែ អ្នកភូមិស្រុកគាត់មកច្រើន ។

ដានី: ពីណាទៀត មានតែ២នាក់ហ្នឹងទេ តាហឹង នឹង តាជៀល?

មុត: បាទ!

ដានី: ហើយមានផ្សេងទៀតអត់?

មុត: មានទៀត តែខ្ញុំអត់ស្គាល់គេ ខ្ញុំឃើញតែជំនិតចំណាស់ដែលចេញចូលមកគឺគាត់ហ្នឹងឯង ។

ដានី: ដល់ពេល តាវ៉ាល់ ជាអនុប្រធានគាត់ ហើយមានតាណាខ្លះទៀត?

មុត: តាវ៉ាល់ ដូចជាអត់ឃើញមានអ្នកណាមករងទេ មានតែអ្នកបន្តបន្ទាប់ពីគាត់មក ឃើញមានតែ តាវ៉ាល់ មួយដែលនៅក្ដាប់រួមនោះ ចេញចូល ហើយឥវ៉ាន់ក៏ច្រើន ឃើញតែ តាវ៉ាល់ តាវ៉ាល់ សង្ស័យតែគាត់ទទួល ។

ដានី: ចុះកាលហ្នឹងគណៈស្រុកព្រះនេត្រព្រះពីណាគេ?

មុត: គណៈស្រុកព្រះនេត្រព្រះគឺ តាម៉ោង រងតាម៉ោង តាសំអាត បើស្រុកបានគេមានតួលេខ ។

ដានី: គណៈស្រុកព្រះនេត្រព្រះមិនមែន តាវ៉ាល់ ទេ?

មុត: ចៅហ្វាយស្រុកព្រះនេត្រព្រះ ។

ដានី: តាម៉ោង អញ្ចឹង តាវ៉ាល់ អត់មានធ្វើគណៈស្រុកទេ?

មុត: អត់ទេ មិនដឹងថាបែបជាសាខាគេ តាមមុខសញ្ញា ។

ដានី: តាអាត ដែរ?

មុត: តាសំអាត ក្រោម តាម៉ោង ។

ដានី: តែ២នាក់ហ្នឹងទេ?

មុត៖ បាទ! ២នាក់ ។

ដានី៖ គណៈស្រុកព្រះនេត្រព្រះ?

មុត៖ បាទ! មានតែ២នាក់គត់ តាម៉ោង តាសំអាត ហើយ តាវ៉ាល់ នេះឃើញដោយឡែក សង្ស័យដាច់ចេញពីស្រុកទៅនៅកាន់តំបន់ ។

ដានី៖ គណៈតំបន់?

មុត៖ បាទ! ព្រោះឃើញ តាហ៊ីង ចេញចូលដែរ ។

ដានី៖ តាហ៊ីង ចេញចូលមកណា?

មុត៖ ចេញចូលមកផ្ទះ តាវ៉ាល់ តាអីតែមិនដឹងថាយ៉ាងម៉េច ។

ដានី៖ ផ្ទះ តាវ៉ាល់ នៅណា?

មុត៖ ផ្ទះ តាវ៉ាល់ នៅមាត់ស្រះចុងខាងជើងសព្វថ្ងៃនេះ ផ្ទះក្បឿងនៅខាងត្បូងផ្ទះ តាហ៊ីង នៅខាងលិចមាត់ស្រះ ផ្ទះក្បឿងធំ ។

ដានី៖ អញ្ចឹងមន្ទីរតំបន់៥ នៅណា?

មុត៖ មន្ទីរតំបន់៥ នៅស្វាយស៊ីសុផុន ។

ដានី៖ ប៉ុន្តែផ្ទះ តាហ៊ីង គាត់នៅនេះ?

មុត៖ បាទ! គាត់នៅនេះ មកនៅជប់ ផ្ទះ តាសំអាត មួយ ផ្ទះ តាម៉ោង នៅបៀតវត្តគោកថាយ នៅជប់វ៉ារីយើងហ្នឹង ខាងជើងផ្លូវចូលទៅវត្តគោកថាយខាងជើង ។

ដានី៖ ចុះ តាជៀល គាត់នៅណា?

មុត៖ តាជៀល នៅស្វាយ ។

ដានី៖ តាជៀល គាត់នៅស្វាយ?

មុត៖ បាទ! កូន តាញឹម គណៈភូមិភាគ ។

ដានី៖ ចុះពូដែលឃើញមុខគាត់ទេ តាជៀល?

មុត៖ ឃើញ ។

ដានី៖ តាជៀល កាលហ្នឹងគាត់អាយុច្រើនជាងពូច្រើន?

មុត៖ ច្រើនជាង ។

ដានី៖ ចាស់ដែរ?

មុត៖ បាទ! តាជៀល ម៉ាជំនាន់ដែលខ្ញុំនៅនោះ តាជៀល ពីសម័យខ្ញុំនៅនោះអាយុគាត់ប្រហែលជា ៤០ ។

ដានី៖ គាត់៤០?

មុត៖ បាទ!

ដានី៖ អញ្ចឹង តាញឹម អាយុច្រើនកាលហ្នឹង?

មុត៖ តាញឹម ៦០ ។

ដានី៖ ហើយចុះ តាហឹង?

មុត៖ តាហឹង មនុស្សប្រហែលជា៥០ ។

ដានី៖ អាយុច្រើនជាង តាជៀល?

មុត៖ បាទ! ច្រើនជាង ។

ដានី៖ ចុះ តាវ៉ាល់?

មុត៖ តាវ៉ាល់ អាយុប្រហែលជា៤៨ ឬ៤០កន្ទុយធំណាស់ ក្បែរ៥០ហ្នឹង ព្រោះពួកនោះរៀន គាត់សាស្ត្រាចារ្យ គាត់នៅកំពង់ចាម ។

ដានី៖ អ៎! គាត់អ្នកកំពង់ចាម តាវ៉ាល់?

មុត៖ បាទ!

ដានី៖ រាងរៅគាត់យ៉ាងម៉េច?

មុត៖ រាងរៅគាត់ស្គមស្ដើង ចង្កេះអង្រង ហើយ តាវ៉ាល់ នឹង តាសំអាត ដូចគ្នារាងរៅតែមួយ ។

ដានី៖ រាងស្គម ហើយខ្ពស់ទេ?

មុត៖ ខ្ពស់ ធ្មេញមាស សម្បុរខ្មៅ មុខស្រួច បានប្រពន្ធសកល្អ សព្វថ្ងៃបានកូនមួយឈ្មោះ អាដួង កូន តាវ៉ាល់ ហើយនឹងយាយគិន កូនគេមកពីព្រៃ ។

ដានី៖ អញ្ចឹងកូនគាត់នៅរស់ទេ?

មុត៖ កូនគាត់នៅរស់តើ កូនជាមួយយាយគិន ។

ដានី៖ យាយគិន?

មុត៖ បាទ! ប្រពន្ធ តាវ៉ាល់ ចាប់ តាវ៉ាល់ ក៏បែកបាក់គ្នាទីណាត់ទីណែងទៅ ។

ដានី៖ យាយគិន ហ្នឹងប្រពន្ធ តាវ៉ាល់?

មុត៖ បាទ!

ដានី៖ ហើយប្រពន្ធ តាវ៉ាល់ ហ្នឹងនៅភូមិអីគេ?

មុត៖ ភូមិអីទេ ក្បែរស្ពានស្រែង ។

ដានី៖ កូនគាត់ឈ្មោះអី?

មុតៈ កូនគេប៉ុនៗនេះដែលខ្ញុំនៅ ដែលបែកបាក់គេចាប់ឪហ្នឹងកូនប៉ុនៗនេះ គាត់ហៅតែ អាដូងៗ ដូចថាឪ ហៅ អាដូង ផង អាដូច ផង ។

ដានីៈ ដូង ឬ ដូច?

មុតៈ បាទ!

ដានីៈ អញ្ចឹងបើទៅសួរគេអ្នកស្ពានស្រែងគេស្គាល់ហើយ យាយគិន ប្រពន្ធ តាវ៉ាល់?

មុតៈ បាទ! យាយគិន ប្រពន្ធ តាវ៉ាល់ បើសិនណាទៅរកក្នុងភូមិស្ពានស្រែងមិនឃើញទេ បងឯង សួររកភូមិគុំភ្នាង ព្រោះគាត់កាលបែកនោះខ្ញុំសួរអ្នកស្ពានស្រែងគាត់អាចដឹងហើយ កាលសម័យនោះវាបែកបាក់គ្នារហូត តែមិនដឹងថាគេនៅពិតប្រាកដយ៉ាងណាឥលូវ ។

ដានីៈ អញ្ចឹងកាលគេចាប់ តាវ៉ាល់ ទៅប្រពន្ធកូនអត់អីទេ?

មុតៈ អត់អីទេ គេទៅរកស្រុកកំណើតគេវិញ អ្នកស្រុកស្រែយើងដែរ ។

ដានីៈ ចុះបើតាមពូស្គាល់ តាហឹង រាងគាត់យ៉ាងម៉េចដែរ?

មុតៈ តាហឹង រាងគាត់មិនជាខ្ពស់ប៉ុន្មានទេ រាងសឹងថាបើនៅសព្វថ្ងៃរាងវៀខ្ញុំ កំពស់ទាប មនុស្សខ្មៅស្រអែម ខ្មៅក្រហមស្អាត ស្រអែមស្រស់ ។

ដានីៈ សក់គាត់យ៉ាងម៉េច?

មុតៈ សក់គាត់មិនជារួញទេ សក់ស្ដូតធម្មតា មិនជារួញមិនជាអីទេ តាហឹង ។

ដានីៈ ចុះសម្ដីសំដៅគាត់?

មុតៈ សម្ដីសំដៅគាត់ដូចជាអ្នកស្រុកជាមួយ និយាយរបៀបដូច តាម៉ោង ដែរ ខ្ញុំសង្ស័យអ្នកសំឡូត ព្រោះ តាម៉ោង គាត់អ្នកស្រុកសំឡូត ។

ដានីៈ អញ្ចឹងមិនមែនអ្នកកំពង់ចាមទេ ដូច តាម៉ោង ។

មុតៈ ដូច តាម៉ោង ព្រោះ តាម៉ោង អត់មានអ្នកកំពង់ចាមទេ អាស៎ តាហឹង ។

ដានីៈ តាហឹង?

មុតៈ តាហឹង អត់មានអ្នកកំពង់ចាមទេ គាត់គណៈតំបន់ ។

ដានីៈ គាត់អ្នកចេះដឹងដែរមើលទៅ?

មុតៈ ចេះ ពួក តាសំអាត តាវ៉ាល់ សុទ្ធតែអ្នកចេះ ។

ដានីៈ តាហឹង ហ្នឹងសម្ដីសំដៅគាត់និយាយរបៀបអ្នក?

មុតៈ សម្ដីសំដៅ តាហឹង ហើយនឹង តាម៉ោង និយាយដូចគ្នា ហើយនិយាយរាងដាច់ បើ តាម៉ោង រាងញាប់បន្តិច តែ តាហឹង រាងធូន់ តែសម្ដីសំដៅចេញមករាងធូន់ ។

ដានី៖ ចុះ តាជៀល?

មុត៖ តាជៀល បានឡេវឡាវ សម្ដីឡេវឡាវ ព្រោះគាត់អ្នកស្រែអ្នកស្រុកភ្នំស្រុក ។

ដានី៖ អ៊ំ! គាត់អ្នកស្រុកភ្នំស្រុក?

មុត៖ បាទ!

ដានី៖ សម្ដីគាត់រាងម៉េច រាង?

មុត៖ អ៊ំ! តាវ៉ាល់ ដេញមិនទាន់ទេ ញាប់ណាស់ ទាល់តែខ្ញុំចង្អុល សព្វបែបយ៉ាងហ្នឹងមិនដឹងនិយាយថាម៉េច វឡាវ ដាក់ធ្មេញមាស២ ។

ដានី៖ ដាក់ធ្មេញមាស២?

មុត៖ បាទ!

ដានី៖ គាត់សម្បុរយ៉ាងម៉េចដែរ?

មុត៖ សម្បុរខ្មៅ ខ្មៅសក់រួញរាងអង្កាសដីដែរ ។

ដានី៖ ខ្ពស់ឬទាប?

មុត៖ ខ្ពស់ ហើយចង្កេះអង្រែង ។

ដានី៖ ប្រពន្ធគាត់ឈ្មោះអី?

មុត៖ ប្រពន្ធឈ្មោះ គិន គេហៅថាមិត្តគិនៗ ។

ដានី៖ ហ្នឹងប្រពន្ធ តាវ៉ាល់?

មុត៖ ប្រពន្ធ តាវ៉ាល់ ។

ដានី៖ ចុះប្រពន្ធ តាហឹង?

មុត៖ ប្រពន្ធ តាហឹង ខ្ញុំអត់ស្គាល់ទេ បើស្គាល់គឺស្គាល់ ចែរីន គាត់ស្រួលណាស់ ប្រពន្ធ តាម៉ោង ក្ដាប់ពេទ្យស្រុកព្រះនេត្រព្រះ ស្អាតណាស់ ។

ដានី៖ បើប្រពន្ធរបស់ តាជៀល ពូស្គាល់ទេ?

មុត៖ អត់ស្គាល់ គេរៀបនៅស្វាយស៊ីសុផុន មិនដឹងថាគេបានពីណាពីណី ។

ដានី៖ អត់ឮថាប្រពន្ធគាត់ត្រូវជាកូនរបស់ ស ភឹម អីទេ?

មុត៖ អត់ឮទេ ប្រហែលជា តាញឹម ហើយនឹង ស ភឹម មិត្តភ័ក្ដ្រគ្នាហើយ រាងសង្ស័យដែរតែខ្ញុំអត់ ច្បាស់ទេ គ្រាន់តែខ្ញុំមានការសង្ស័យ ព្រោះខ្ញុំឮដែរខ្ញុំភ្លេចមួយភាំងទៅ ប្រហែលជាមិត្តភ័ក្ដ្រ គេ អាចបានជាដណ្ដឹងគ្នាមិនដឹង ។

ដានី៖ តែពូអត់ដឹងថាប្រពន្ធគាត់ឈ្មោះអីទេ?

មុត៖ អត់ដឹងទេ ។

ដានី៖ ហើយ តាហឹង ពូស្គាល់ប្រពន្ធគាត់ដែរ?

មុត៖ តាហឹង អត់ស្គាល់ទេ ស្គាល់តែ តាម៉ោង ។

ដានី៖ ស្គាល់តែ តាម៉ោង ហើយនឹង តាវ៉ាល់ទេ?

មុត៖ បាទ!

ដានី៖ ចុះពូ កាលពេលដែលពូចូលទៅ តាវ៉ាល់ ជ្រើសចូលទៅកងចល័តរបស់ តាវ៉ាល់ ហើយកាលហ្នឹងពូមានតួនាទីអីដែរ?

មុត៖ ខ្ញុំចូលទៅតែមួយដង គឺជាគេតែងតាំងឲ្យទៅជាមេកងអនុសេនាធំទី៣ នៅកងចល័តរបស់ តាវ៉ាល់ ហ្នឹងឯង ។

ដានី៖ មេកងអនុសេនាធំ?

មុត៖ បាទ! គេរៀបបងប្អូនដែលជម្លៀសមកពីភ្នំពេញមក គេឲ្យខ្ញុំកាន់នៅហ្នឹងឯង ។

ដានី៖ អនុសេនាធំទី៣ហ្នឹងមានគ្នាប៉ុន្មាននាក់ទៅ?

មុត៖ មានគ្នាដល់ទៅ១០០នាក់ជាង ជួនណាមាន១២០ ហើយមានពីណាពីណីមិនទៀងទេ គេយកពីណាពីណីមកឲ្យ ។

ដានី៖ ប្រហែល១០០?

មុត៖ ១០០ជាង ។

ដានី៖ អញ្ចឹងដូចជាមួយចល័តតំបន់ហ្នឹងវាមានគ្នាប៉ុន្មានទៅ?

មុត៖ មួយចល័តតំបន់ច្រើន ព្រោះវាមានកងធំទី១ តាវិត នៅស្រែះ នៅដូនប្រែង ទី២ ផន នៅល្ហាល ទី៣ខ្ញុំ មាន៣កងអនុសេនាធំ ហើយស្រី៣កងដូចគ្នា ។

ដានី៖ អញ្ចឹងកងអនុសេនាធំ តាវិត?

មុត៖ តាតែ ។

ដានី៖ តាវិត នៅ?

មុត៖ តាវិត នៅកងធំទី១ កងអនុសេនាធំទី១ ហើយកងអនុសេនាធំទី២ឈ្មោះ ផន អ្នកល្ហាលខាងកើតជាប់នេះ ប៉ុន្តែស្លាប់ហើយសព្វថ្ងៃ គាត់ខ្មែរក្រហមស្លាប់នៅភ្នំឆ័ត្រ ។

ដានី៖ ចុះ តាវិត?

មុត៖ តាវិត រត់គៀសខ្លួនពីអាងត្រពាំងថ្មហ្នឹងឯង រត់ទៅថៃទៅ ទៅផ្លូវនេះឯង បាត់ខ្លួនប៉ុន្មាននាក់ច្រើនដែរ ។

ដានី: អញ្ចឹងកងបុរសមានពាកងអនុសេនាធំ?

មុត: បាទ! ៣កងអនុសេនាធំ ។

ដានី: ហើយកងខាងស្រីមាន៣កង?

មុត: មាន៣កង មានកងថៃម៉ៅ កងអនុសេនាធំទី១ កងអនុសេនាធំទី២ បងមិត បងមិតក្តាប់រួមដែរ នៅស្ពានស្រែងដែរបងមិត ខ្ញុំប្រាប់រួចហើយអាហ្នឹងក្តាប់រួមស្រីៗ ខ្ញុំភ្លេចស្រីៗ មិនដឹងថាខ្ញុំសង្ស័យមិនដឹងថានារី កេន ប្រពន្ធ តារៀប ដែលនៅភ្នំលាភហ្នឹងឯងមេកងធំទី២ដូច ជនមេកងធំទី២គឺ កេន នេះឯង ឈ្មោះ កេន ប្រពន្ធ តារៀប អានោះធ្វើទាំងប្តីទាំងប្រពន្ធនៅហ្នឹង គេរៀបនោះដូចគ្នា គេកងធំទី៣ ។

ដានី: តារៀប គាត់ធ្វើអី?

មុត: តារៀប មេកងក្តាប់យុទ្ធជន ដល់ក្រោយមកទៀតគេរៀបតែងតាំងឲ្យក្តាប់កុមារ សារៀបហ្នឹងនៅជាមួយខ្ញុំដូចថាកងតូច ។

ដានី: ម៉េញឈ្មោះ ម៉ៅ ឈ្មោះ កេន ហើយមានអ្នកណាទៀតដែលធ្លាប់ជាអនុសេនាធំនារី?

មុត: កេន នៅដូនប្រែង អាស៍ កេន នៅភ្នំលាភ ហើយថៃ ម៉ៅ នៅដូនប្រែង កងអនុសេនាធំមេកងគណៈតំបន់ ។

ដានី: កេន ហើយនឹង ម៉ៅ ពូស្គាល់តែពីរទេ ក្រែងបីនៅមួយទៀត?

មុត: បាន កេន?

ដានី: បាន កេន ហើយនឹង ម៉ៅ បានពីរនាក់?

មុត: មួយទៀតនោះគាត់អនុសេនាធំដូចខ្ញុំដែរ ទី៣ ឈ្មោះ ភាន់ គាត់អ្នកស្រុកនៅខាងកើតនោះគាត់នៅសៀមរាបឆ្លងទៅដែន ម៉ាចូលស្ពានស្រែងហ្នឹងក៏ប៉ុន្តែឆ្លងទំបន់ ដូចរាងអាសេមអាសាមអាទី៣ ដូចថាវាមានហើយនៅក្នុងកងធំទី៣ មានស្គាល់ខ្លះ ហើយអាមេកងសង្ស័យតែប្រពន្ធព្រោះធ្វើ ការជាមួយគ្នា ប្រជុំជាមួយគ្នា ខ្ញុំភ្លេចវាមានអ្នកស្រុកជិតឯងហ្នឹង មានអ្នកឆ្ងាយបើមិនពាក់ពន្ធ ត្រពាំងថ្មទេ អ្នកខាងនេះឆ្លងដែនទៅខាងសៀបរាប ហើយអ្នកសៀបរាបឆ្លងមកខាងនេះ ឆ្លងមកវាព្រំប្រទល់ស្ពានស្រែងនឹងភ្នំស្រុក ស្រុកភ្នំស្រុកជាមួយគ្នា គេជិតប៉ុណ្ណោះគេនៅខាងជិត ព្រំប្រទល់គេរត់ឆ្លងមកខាងតំបន់៥ ។

ដានី: អញ្ចឹងពូកាលហ្នឹងម៉ាកងចល័តតំបន់ហ្នឹង មាន៣អនុសេនាធំខាងបុរស ហើយនឹង៣អនុសេនាធំខាងនារី?

មុត: បាទ!

ដានី៖ មានតែប៉ុណ្ណឹងទេ ទាំងអស់៦អនុសេនាធំ?

មុត៖ អានោះផ្នែកតែយុទ្ធជនសុទ្ធ នៅក្រុមមេកណ្តាលគេមានក្តាប់ស្រីក្តាប់ប្រុសដែរ តាឈួន ហើយនឹង យាយភឿន ហ្នឹងឯង គេក្តាប់ពួកដូចថាគេរៀប អង្គការរៀបចំអាពាពិពាហ៍ឲ្យ រៀបចំចាប់ដៃរួចក៏ តាឈួន អ្នកក្តាប់ ក្តាប់ពួកមេកណ្តាល មានទៀតគេបែងចែកឲ្យអ្នកកម្លាំង ប្រភេទទី២ទៀត ។

ដានី៖ វ័យកណ្តាល វ័យកណ្តាលហ្នឹង តាឈួន ហ្នឹងអ្នកក្តាប់?

មុត៖ តាឈួន អ្នកក្តាប់ ។

ដានី៖ វ័យកណ្តាលប៉ុន្មានទៅ?

មុត៖ វ័យកណ្តាលដូចថាមាន២០-៣០គ្រួសារអញ្ចឹង គឺ តាឈួន គាត់អ្នកក្តាប់ អានោះគេធ្វើការ ផ្សេងពីយើង អត់មានយកមកវល់វើកជាមួយកម្លាំងតាមកងរបស់យើងទេ ។

ដានី៖ វ័យកណ្តាល តាឈួន អញ្ចឹងមានពីរ មានយុវជនហើយនឹងយុវនារី ហើយនឹងវ័យកណ្តាល?

មុត៖ បាទ! វ័យកណ្តាល ដែលគាត់ជាវ័យកណ្តាលនេះវាចេញពីប្រភព ពីក្នុងកងនារីយុទ្ធជននេះឯង ព្រោះគេអ្នករៀបហើយ គេចាត់ទុកមួយកន្លែង ចេញពីប្រភពនេះឯងតែមួយ ក៏ប៉ុន្តែអត់ទៅ ណាទេ ។

ដានី៖ អ្នកមានគ្រួសារ?

មុត៖ បាទ! អ្នកមានគ្រួសារ ប៉ុន្តែជួនណា គាវ៉ាល់ ហ្នឹងគាត់បញ្ជាទៅ ជួនកាលគាត់មិនបានឲ្យមក លើកដីដូចគេទេ គាត់ចាត់មកតាមផ្នែក១ៗទៅ គាត់ឲ្យទៅដាំជាបន្លែ ឬឲ្យទៅនៅកន្លែងនេះកន្លែង នោះទៅ ។

ដានី៖ អញ្ចឹងបើសរុបទាំងអស់ទៅប្រហែលប៉ុន្មានទៅ?

មុត៖ សរុបទាំងអស់ សរុបទាំងកម្លាំង កម្លាំងច្រើន ទាំងកម្លាំងផ្សេង តែជួនណាខ្ញុំសង្ស័យអាកម្លាំង ដែលមកដែលប្រាប់ថាមាននៅក្នុងស្រុកហ្នឹងនេះទៀតហ្នឹង

ខ្ញុំសង្ស័យតែគេបញ្ជូនតាមសហករណ៍ ទៅទៀត ក្រោយមកទៀតខ្ញុំអត់ចាំក្រលិក្រលៀកតាមបែបដែលគេបញ្ជូនទៅតាមសហរកណ៍ ដែល គាវ៉ាល់ ត្រូវការកម្លាំងហ្នឹង គេឲ្យគ្រប់សហរកណ៍ទាំងអស់តាំងពីស្រុកថ្មពួក ពីស្រុក ណាស្រុកណីហ្នឹងគេបញ្ជូនទៅតាមសហករណ៍គេ ប្រហែលជាមានមែន ព្រោះមានដូចពួកឃឹម ហើយនឹងគ្រូលេខហ្នឹងអត់បានទៅពីកងអើយដូចខ្ញុំទេ ដំណើរបែបទៅក្រលៀកក្រោយគេ

យកទៅដាក់រួមជាមួយសាលាតំបន់ គេទៅតាមសហករណ៍ ស្បៀងអាហារគេចែកពីសហករណ៍ទៅម្តង គេអត់មានវល់វិជាមួយសាលាតំបន់ទេ ប្រហែលមាន ។

ដានីៈ មានតែពូក្តាប់អត់បានអាហ្នឹង?

មុតៈ ក្តាប់អត់បាន ។

ដានីៈ អញ្ចឹងប្រហែលជាមានខាងឃុំខាងអីហ្នឹង គេមានបញ្ជូនគេហៅចល័តឃុំចល័តអីហ្នឹង?

មុតៈ បាទ!

ដានីៈ គេជួយ?

មុតៈ បាទ! គេជួយ ដូចថាដែនការវែសម្រុកអញ្ចឹងគេឲ្យជួយសម្រេចអញ្ចឹងណា៎ តាំងពីស្រុកបន្ទាយឆ្មា អាងដើងគ្រោះអីឃើញទៅដែរ គ្រប់ស្រុកទាំងអស់ សេរីសោភ័ណ្ឌ ។

ដានីៈ ពូដំបូងយើងចាប់ផ្តើមកសាងទំនប់អាងត្រពាំងថ្មដំបូងពីឆ្នាំណាទៅ?

មុតៈ ចាប់កសាងឆ្នាំ៧៦ឡើងទៅលើខាំង ម៉ាកងរហូត ម៉ាកងរហូតទល់ឆ្នាំ៧៧-៧៨បានបែកបាក់គ្នាព្រោងព្រាតចាប់ ចាប់ផ្តើមចាប់ ចាប់មេកងយកទៅរៀននេះរៀននោះ បែកបាក់គ្នា ។

ដានីៈ កាលហ្នឹងពេលពូចូលទៅជាមួយកង តាវ៉ាល់ ហ្នឹង ដូចខាងទំនប់ត្រពាំងថ្មគេចាប់ផ្តើមធ្វើនៅ?

មុតៈ គេអត់ទាន់ធ្វើផង មានតែពួកខ្ញុំ មានតែពួក តាវ៉ាល់ បន្តិចបន្តួចហ្នឹងឯង តែដល់យូៗទៅវាច្រើន ។

ដានីៈ អញ្ចឹងពូ អ្នកដែលទៅដំបូងគេបំផុតដែលចាប់ផ្តើមធ្វើទំនប់ហ្នឹងដំបូងនាំពូទៅដំបូងគេបំផុត?

មុតៈ ខ្ញុំទៅ ខ្ញុំទៅឃើញតែម្តង ឃើញមនុស្សគម្រោងដោតជាឈើចាទុកសម្រាប់ថា អានេះទំនប់កេងទៅណាទៅណី ហើយអានេះបណ្តោយ ខ្ញុំទៅគេបញ្ជូនគឺថាមានធ្វើតែម្តង ទៅធ្វើតែម្តងគ្មានពិបាកនៅចាំដែនការអីទេ អត់ទេ អ្នកវាស់ មានគេអ្នកវាស់មិនទាន់ដកខ្លួនចេញផង មានក្រុមគេអ្នកវាស់ផ្សេង អត់មានវល់វិទេ យើងដឹងតែពីលើក ។

ដានីៈ អញ្ចឹងពេលដែលពូចូលទៅដើមឆ្នាំ៧៧ហ្នឹង ពេលចូលជាកងចល័តធ្វើជាមេកងអនុសេនាធំទី៣ហ្នឹង ពូត្រូវទៅកន្លែងត្រពាំងថ្មហ្នឹងហ្មងឬក៏មិនទាន់ទេ?

មុតៈ ចូលនៅឆ្នាំ៧៧ហ្នឹងទៅតែម្តង ចេញពីជប់ទៅ ចេញពីឆាងទៅ គឺថាគេយកខ្ញុំទៅដាក់ហ្នឹងហ្មង ។

ដានីៈ ទៅត្រពាំងថ្មតែម្តង?

មុតៈ បាទ!

ដានីៈ កាលហ្នឹងនៅជារបៀបបោះអាសី បោះគម្រោង ពេលពូទៅឃើញគេបោះគម្រោងហ្មង?

មុតៈ បាទ! ឃើញគេបោះគម្រោង គេយកខ្នងប៉ុន្មាន ទទឹងប៉ុន្មាន បណ្ដោយប៉ុន្មាន គេតម្រូវឲ្យយើង ហ្នឹង តាវ៉ាល់ ហ្នឹងហៅផែនការមេៗទៅប្រាប់ដូចថា គេយកខ្នងប៉ុណ្ណេះ កំពស់ប៉ុណ្ណេះ គេចាប់ ផ្ដើមមានផែនការមានតែកម្លាំង ហើយភ្លឺឡើងដឹងតែវាស់ម៉ែត្រគេឲ្យកម្លាំង ។

ដានីៈ អញ្ចឹងពូកាលហ្នឹង បើតាមពូនៅចាំដូចថាគេយកខ្នងទំនប់ហ្នឹងប៉ុន្មានម៉ែត្រ?

មុតៈ ខ្នងទំនប់កាលដែលខ្ញុំ ខ្នងលើ៨ម៉ែត្រ តែចិញ្ចើមវាទេ ជើងទេប៉ុន្មានទេ កំពស់ខ្នងលើ៨ម៉ែត្រ កំពស់ជើងទេវាប្រហែលជា១២-១៣ម៉ែត្រ ខ្ញុំស្មាន ខ្ញុំភ្លេចអាទេជើងវា អាជើងទំនប់ខាងនេះ កំពស់ជើងទំនប់ប្រហែលជា១២ម៉ែត្រ ហើយបាតក្រោមមិនដឹងប៉ុន្មានទេ ខ្ញុំដឹងតែខ្នងលើ ។

ដានីៈ បាតក្រោមអញ្ចេះអត់ដឹងទេ?

មុតៈ បាតក្រោមអត់ដឹង ដឹងតែជើងទេនោះ អាទេសងខាងហ្នឹង ។

ដានីៈ អាបាតក្រោមអត់ច្បាស់ទេ?

មុតៈ បាតក្រោមអត់ច្បាស់ទេ ។

ដានីៈ ចុះបណ្ដោយ?

មុតៈ បណ្ដោយវែងណាស់លោកគ្រូ អត់ស្មានថាមានបណ្ដោយវែងអញ្ចឹងទេ ចាប់ពីកែងមកអាងទាំង អស់ ពីស្រុកពង្រជាប់ទៅកូនខ្លែង ភ្នំកូនខ្លែងចាស់បត់បែន អាងនោះវាបត់បែន ទាល់តែមាន ដែនទីភូមិត្រពាំងថ្ម ហើយភូមិត្រពាំងថ្មវាទៅអញ្ចេះចំភូមិសំបួរ ភូមិពង្រចាក់ទៅខាងជើងទៅ ទងអាដើមព្រៃភ្នំកូនខ្លែង ចាប់មកផ្លូវខាងលិចវិញ ចាប់មកដល់ស្ពួងស្ពានទី២ទី៣ រហូតដល់ តាវ៉ង ឆ្ងាយដែរ ។

ដានីៈ ពូអាចគូសបានទេ ពូគូសពីដំបូងចាប់ចេញម៉េច ពូគូសកន្លែងនេះ?

មុតៈ មើលខាងកើត ឯណាខាងកើតភូមិត្រពាំងថ្ម កៀនផ្លូវចូលត្រពាំងថ្ម អានេះភូមិត្រពាំងថ្ម យើង មានផ្លូវទៅលិចមកពីត្រពាំងថ្មមកលិច មកលិចមានស្ពានដែលបើកចេញចូល នេះស្ពាន គេ ហៅស្ពានទី១ បន្ទាប់មកទៀតមកលិចទៀត អានេះលិចណាំស្ពានទី២ មកលិចទៀតគេហៅស្ពាន ទី៣ ហើយមកទៀតគេហៅស្ពួង គេហៅស្ពានទី៣គេហៅស្ពួង បន្ទាប់មកទៀតមកដល់តាវ៉ង ចាក់មករកតាវ៉ងដាច់មកអត់មានស្ពានទៀតទេ មានតែស្ពានទី១ទី២ទី៣ បន្ទាប់មកទៀតតាវ៉ង ។

ដានីៈ ចុះពីទីនេះ?

មុតៈ ទីនេះភូមិត្រពាំងថ្ម ។

ដានីៈ ត្រពាំងថ្មពីខាងកើត?

មុតៈ ខាងកើត ។

ដានីៈ កើតហើយបានមកដល់ខាងលិច?

មុតៈ បាទ! ខាងកើតហើយមកខាងលិច តែភូមិអ្នកស្រុកគេនៅខាងកើត ខាងកើតអាង ហើយមានផ្លូវខ្វែងទំនប់នេះឯង ខ្វែងទំនប់មកខាងលិចរហូត ចាប់ផ្ដើមមកបានមានស្ពានទី១ទី២ អានេះមានដាងទេនសម្រាប់ធ្វើហើយនឹងដាងមុនវិសុករ ហើយកាលហ្នឹង គាវ៉ាល់ យកមកធ្វើហ្នឹង ធ្វើបានសម្រេចជោគជ័យហើយស្ពានទាំងអស់នោះមេម៉ាយ

ដល់មកមេម៉ាយអាស្ពានរន្ទះបាញ់នេះ មេម៉ាយធ្វើអត់រួច

អានេះបានសម្រេចរបស់គាត់អស់អាលីង ខ្ញុំដេកនៅតាមស្ពាន ។

ដានីៈ អញ្ចឹងត្រពាំងថ្មហ្នឹងចាប់ផ្ដើមធ្វើមកត្រឹមតាវែង អត់មានអ្នកណាទៀតទេ?

មុតៈ បាទ! ម៉ាកេងម៉ាបត់ត្រឹមហ្នឹងទៀត អានេះពីខ្ញុំធ្វើណា៎ ពីខ្ញុំធ្វើបានប៉ុណ្ណេះឯង ។

ដានីៈ ចុះម៉េញពូថាមានទៅភ្នំកូនខ្វែង?

មុតៈ បាទ! ភ្នំកូនខ្វែង មកខាងកើត នេះលោកគ្រូនេះ អានេះភូមិណាលោកគ្រូ ហើយអានេះកៀនភូមិ កៀនភូមិចំងាយពីភូមិប្រហែលជា១០០ម៉ែត្រមកមានបត់ទៅភូមិ គេហៅភូមិសំបួរ បន្ទាប់ពីសំបួរ ពង្រ អានេះភូមិមួយទៀតភូមិពង្រ ។

ដានីៈ អញ្ចឹងទំនប់យើងធ្វើពីហ្នឹងមក ពីខាងជើងមក?

មុតៈ ធ្វើពីខាងត្បូង ធ្វើពីខាងត្បូងដែលរៀបចំៗពីខាងត្បូងមកខាងកើត ភូមិនេះមានមួយកំណាត់មកបានចេញពីភូមិនេះមកបានធ្វើពីអ្នកធ្វើមកខាងលិចក៏មកទៅ ហើយអ្នកធ្វើមកខាងនេះក៏មកទៅ ចាក់មកទីនេះវាកែងណាលោកគ្រូ កែងទៅខាងជើង កែងពីភូមិត្រពាំងថ្មមកមកចូលភូមិសំបួរ សំបួរហើយពង្រ ហើយតពីពង្រមកទៀតទៅព្រៃកូនខ្វែងទៀត តែខ្ញុំដាក់អត់អស់ណាលោកគ្រូ មានទៀតអត់ទាន់ចប់ត្រឹមហ្នឹងទេ ដល់ក្រោយមកទៀតគេធ្វើបានច្រើនទៀតណាលោកគ្រូ គេថែមថយឲ្យទៀត ។

ដានីៈ ព្រៃកូនខ្វែងទៀត?

មុតៈ បាទ! ព្រៃកូនខ្វែង ។

ដានីៈ អញ្ចឹងគេធ្វើតពីនេះមកទៀតអញ្ចឹង?

មុតៈ បាទ! ធ្វើត ក្រុមគេគឺគេធ្វើ សព្វថ្ងៃមានគេកែសម្រួលច្រើនទៀត តែខ្ញុំមិនដែលបាននេះ ។

ដានីៈ ប៉ុន្តែពូអត់ដឹងចំងាយពីហ្នឹងមកនេះប៉ុន្មានទេ?

មុតៈ អត់ដែលបានដឹងថាប៉ុន្មានគីឡូទេលោកគ្រូ ដឹងតែវែងដែរ ប្រភេទអាងត្រពាំងថ្មវាកែងអញ្ចឹង វាហ៊ុំព័ទ្ធទៅរកព្រៃកូនខ្វែង អានេះកើត អានេះមកលិច អានេះភូមិ ចង់ដឹងថាខ្ញុំរកអញ្ចេះបាន ឃើញ ព្រោះភូមិនៅខាងកើតអាង ផ្លូវចូល ជាប់ផ្លូវចូលហ្នឹងឯង មានផ្លូវក្រហមមួយនៅក្រាល កណ្តាលភូមិត្រពាំងថ្មមកបានចូលភូមិ អានេះកៀនភូមិ កៀនភូមិមានគេលើកទំនប់មួយ កែង ទៅមានភូមិសំបួរ ភូមិពង្រ បន្ទាប់ពីពង្រទៅ ទៅគោកភ្នំកូនខ្វែង ហើយអានេះក៏ព័ទ្ធដែរ ព្រោះ ព្រៃកូនខ្វែងវាមានចាក់មកនេះវាវង់មកនេះ ភ្នំកូនខ្វែងនៅនេះ អានេះធ្វើទៅរកអានេះឯង វាព័ទ្ធហ៊ុំតើ សព្វថ្ងៃទឹកវានៅនេះឯង ។

ដានីៈ ចុះពូ អាកំពស់យើងឈរអញ្ចឹងប៉ុន្មានទៅ ព្រោះអាជើងទេនោះ១២?

មុតៈ អាកំពស់កាលខ្ញុំធ្វើសព្វថ្ងៃវានៅទាប ព្រោះអានេះចាប់ផ្តើមធ្វើមក ជើងវាប្រហែលជា១២-១៣ ហើយអាជើងទេវាអញ្ចេះណាលោកគ្រូ អានេះមិនខ្ពង?

ដានីៈ បាទ!

មុតៈ អាខ្ពងលើនេះ៨ម៉ែត្រ ហើយអាគេយកទេ ទៅចាក់ទេនោះ ទេឡើងអញ្ចេះ អាខ្ពងទំនប់នោះ វាងខ្ពងអណ្តើកដែរ អាខ្ពងលើនេះយើងដឹងតែ៨ម៉ែត្រពីចិញ្ចើម ពីចិញ្ចើមនេះមកចញ្ចើមនេះដឹង តែ៨ម៉ែត្រ ហើយអាបាតក្រោមទៀតខ្ញុំអត់ចាំច្បាស់ទេ អាបាតក្រោមណាលោកគ្រូ ខ្ញុំភ្លេច ដែរ ព្រោះវាយូដែរ ហើយមានសូវបានយកចិត្តទុកដាក់ណា ។

ដានីៈ ប៉ុន្តែកំពូលវាអត់ដឹងទេ កំពូលដូចថាយើងចាក់ត្រង់អញ្ចេះ?

មុតៈ អ៊ំ! បើសិនជាចាក់ត្រង់ ចំពោះតែជើងទេពាខ្ញុំថាវាមិនខុសពី១០ម៉ែត្រ១២ម៉ែត្រទេ កំពស់ ប្រហែលជា១០ ព្រោះជើងទេយើងយកតែទេយើងយកតែទេ យើងមានវាស់ត្រង់ណា ប្រហែលជាកំពស់១០ម៉ែត្រ ខ្ពង៨ម៉ែត្រ វាមានធម្មតាណា កំពស់ឡើងសន្ទឹមដែរ ដូចជាមិន លើសពី១០ទេកំពស់ហ្នឹង ។

ដានីៈ អញ្ចឹងពូ ដែលយើងទៅប្រជុំនេះ យើងប្រជុំជាមួយ តាវ៉ាល់?

មុតៈ ប្រជុំដូចតាវ៉ាល់គាត់នៅរោង ពួកខ្ញុំធ្វើដូចជាសង់ៗកន្លែង ទាហានដូចថារោងបាតង់ ដូចជារោង ការម៉ាខ្ពងចឹង គេធ្វើប្រភេទដូចរោងការអញ្ចឹងតែយើងបាំងស្បូវបាំងអី បើកងខ្ញុំកងទី១ទី២ទី៣ ដេកអញ្ចេះដូចយើងម៉ារោងៗ ស្រីៗគេម៉ារោងផ្សេង កន្លែងតាវ៉ាល់ បនធំមួយអន្តរអី មានស្រេច សម្ភារៈអន្តរអី គេគោះហៅយើង គេហៅតែមេៗទៅប្រជុំកន្លែងគេ គេអត់មាន មកស៊ីបាយជាមួយយើងទេ ។

ដានីៈ ចុះលោកពូហូបបាយនៅឯណាទៅ?

មុតៈ ខ្ញុំហូបជាមួយកងហ្នឹង។

ដានីៈ ជាមួយកង!

មុតៈ ហូបតាមក្រុមគេ ទោះបីខ្ញុំមកឯហ្នឹង ហូបអត់ដាច់ដោយឡែកទេ។

ដានីៈ យើងហូបនៅជាមួយកងដែរ?

មុតៈ បាទ!

ដានីៈ យើងអត់មានទៅហូបជាមួយគាវ៉ាល់អីទេ?

មុតៈ អត់ទេ! ព្រោះស្បៀងអង្ករគេចែកឲ្យយើងតាមរបបកម្លាំងហ្នឹងឯង។

ដានីៈ អ៊ីចឹង បើពេលប្រជុំ ប៉ុន្មានថ្ងៃប៉ុន្មានអាទិត្យប្រជុំម្តង?

មុតៈ ប្រជុំ! ល្ងាចឡើង បាយរួច ចប់កិច្ចការអីបាយទឹករួច យកស្ថិតិទៅឡើង ចែនោះមួយស្មៀនគាត់ដែរ គាត់សម្រាប់នៅបូកសរុបរួមឲ្យគាត់ទាំងអស់ទាំងប៉ុន្មានកង។ ចែនោះគាតចេះបងប្អូនថ្មីគាត់មក យើញគាវ៉ាល់យកទៅ។

ដានីៈ ចែនោះ ឈ្មោះចែអី?

មុតៈ ឈ្មោះចែអី ខ្ញុំភ្លេចឈ្មោះគាត់ហើយ រាងសគាត់រាងវៃដែរ គាត់នៅកន្លែងសម្រាប់កត់កន្លែងគាវ៉ាល់ គាត់ដូវធំមួយ គាត់សរុបបូក ស្ទាស់ណាស់ចែហ្នឹង យើងយកតាមកងរាយការណ៍ទៅតាមកង កងខ្ញុំ ខ្ញុំយកទៅរាយ កងទី២យកទៅរាយចំនួនរបស់គេ ខ្ញុំកម្លាំងធ្វើការ កម្លាំងសរុប ឈឺប៉ុនណេះ ប៉ុនណោះ បង្ហាញមុខ។

ដានីៈ ឈឺយើងរាយការណ៍ដែរ?

មុតៈ រាយការណ៍កម្លាំងសរុបទាំងអស់ប៉ុន្មាន ដេកពេទ្យប៉ុន្មាន ធ្វើការបានប៉ុន្មាន សម្រាក់នៅកន្លែងប៉ុន្មាន បានគេរកម៉ែត្រគីបឃើញ ៣ម៉ែត្រគីប អត់បាត់ បើបាត់ក៏មិនបានដែរ។

ដានីៈ អ៊ីចឹងពេលហូបបាយល្ងាចហើយយើងទៅរាយការណ៍រាល់ថ្ងៃ?

មុត ៈ បាទ! រាយការណ៍ យើងមកពីធ្វើការវិញបានយើងទៅហូបបាយ ហូបបាយរួចបានយើងធ្វើស្ថិតិបូកពីយើងរួច បានគេបូកបញ្ឈាក់នៅកន្លែងគាវ៉ាលនោះទៀត រកអាចំនួនម៉ែត្រគីបនេះហែ្ងង រកចំនួនដី ហើយខ្ញុំបងប្អូនដែលជីក៣ម៉ែត្រគីបនោះរួច ជីក៣ម៉ែត្រគីបរួច បងប្អូនដូចជាកនេះរួច ហៅខ្ញុំទៅវាស់ គ្នារួចហើយបងឯងមកមើលវាស់ឃើញទៅឡើង តាមដំណើរថ្ងៃប៉ុណ្ណាក៏ដោយ ព្រឹកប៉ុណ្ណាឲ្យតែរួច។

ដានី ៈ ម្នាក់៣ម៉ែត្រគីប?

មុត ៖ ៣ម៉ែត្រគីប សុទ្ធតែរែកទាំងអស់ ។

ដានី ៖ ចុះពូអាចាប់ដីបូនៗ អាទាប់ៗដីបូន ៣ម៉ែត្រគីបដីបូនស្រួលទេណា ដល់យូទៅ កាន់តែខ្ពស់ទៅកាន់តែ....

មុត ៖ បាទ!

ដានី ៖ ចុះពូម៉េចអាដីបូនយើងមិនកាប់ដីបានចាក់ៗទៅ វាមិនខ្ពស់?

មុត ៖ កាលណាយើងធ្វើ យើងមិនទាន់សំអាតម៉ងទេ យើងទុកប្រព័ន្ធឡើងរាងទេៗ រាងធ្វើដូចកាំជណ្តើរ យើងជីកៗវាកុំទាន់រៀបរ៉ាវវាឲ្យល្អដែរ ដល់ចប់យើងយើងចាំឈូសផ្លូវឲ្យបាន ដូចគ្នាអត់ពិបាកទុកផ្លូវឲ្យកំប៉េតកំបូតទេ ធ្វើយកស្អាត់តែរម្តង អត់មានទុកយកផ្លូវណាដែលយើងដើរយកផ្លូវនោះទៅ អត់យកផ្លូវណា ផ្លូវណីទេ យើងហើយពីកន្លែង ទុកផ្លូវមួយដើរ ហើយចាប់បន្តអាមុខតទៀត អាត្រង់ណោះត្រូវចាំងត្រូវហើយអាផ្លូវនេះឲ្យបានស្អាតទៀត ធ្វើឲ្យស្មើដីងទេគេ ។

ដានី ៖ ចុះពូនៅក្នុងកងអនុសេនាធំរបស់ពូ កូនក្រុមរបស់ពូ ពូជ្រើសរើសយ៉ាងម៉េចទៅ ជ្រើសរើសមកពីណាទៅ?

មុត ៖ អានេះ គេចងក្រងឲ្យ មិនមែនយើងជ្រើសរើសខ្លួនយើងទេ ដូចថាខ្ញុំកាន់កងទី៣ កងនោះយ៉ាប់ សួរតែលោក នួន ណារិន នោះដឹងហើយ កងទី៣ នោះច្រើនតែ ដូចថាកម្លាំងប្រភេទទី៣អន់ខ្សោយ ហឺគ្មានផិតមាន់ ផផិតអីផង ហឺគេរៀនមកឲ្យកងខ្ញុំកាន់ផផិតមាន់ពួកខ្វាក់មាន់ណា បាទ! ពួកខ្វាក់មាន់ហ្នឹងគេហៅកងទី៣ ទី២នោះគេហៅកម្លាំងទី២ មិនសូវមានឈឺ ដល់កម្លាំងពូងផិតមាន់របស់ខ្ញុំ សូម្បីតែទៅធ្វើយប់ទៀត ទៅធ្វើដូចថាអ្នកមិនទាន់រួច ដូចថាដើរចាប់ដើរអី បើមានដែនការសម្រុកអីដើរតោងគ្នា ស្តាយចប់ស្តាយបន្តីរដើរតោងគ្នា ព្រោះផផិតមាន់ បាទ! ផផិតមាន់ ។

ដានី ៖ អីចឹងក្នុងកងរបស់ពូហ្នឹងជាប្រជាជន ជាយុទ្ធជនចាស់ផង ថ្មីផង?

មុត ៖ បាទ! ប្រជាជនចាស់តិច ប្រជាជនចាស់មានតែពួកវ៉ាន់, ចក់ ហឺខ្ញុំ ចក់នោះ កងអនុសេនាតូចហឺខ្ញុំក្តាប់ ចំណុះកងអនុសេនាធំខ្ញុំដែរ ចក់នោះណា ហឺ វ៉ាន់ ហឺរ៉ុក នោះមេក្រុម ដល់ពេលគេអ្នកស្រុក អ្នកភូមិជាប់គ្នាអីចេះ ខ្ញុំក្តាប់ដូចកូនសិស្ស ខ្ញុំស្គាល់ ដល់ខ្ញុំនើយហត់ទៅខ្ញុំប្រគល់ឲ្យវ៉ាន់ ឲ្យរ៉ុក ឲ្យពួកបូកស្ថិតិ យកទៅឡើងហ្នឹងគេ អាពួកនោះ រៀនថ្នាក់ទី៣ ពីសង្គមគ្នាបានខ្ញុំឱបរក្សាទុកទៅ គ្នាបានរស់រាណ ពួកវ៉ាន់, ចក់ អីសុទ្ធតែកូន សិស្សសាលាលីសេក្រឡាញកាលពីដើមៗ ដែលគ្នាសុទ្ធតែចៅចិនដែរ នោះ ។

ដានី ៖ ក្រោយពីនោះសុទ្ធតែប្រជាជនថ្មីទេ?

មុត ៖ ប្រជាជនថ្មីមកពីភ្នំពេញទាំងអស់ ។

ដានី ៖ កាលហ្នឹងដឹងតែបែងចែកធ្វើម៉េចឲ្យរួច៣ម៉ែត្រគីប?

មុត ៖ បាទ! ៣ម៉ែត្រគីប ហ្នឹងតាវ៉ាល់ គាត់ដាក់ផែនការ ធ្វើម៉េចឲ្យរួច តាវ៉ាល់ថា មិត្តបើមិនរួច៣ម៉ែត្រគីបទេ មិនបាច់មកជួបខ្ញុំទេ ។

ដានី ៖ គាត់ថាអីចឹងម៉ង?

មុត ៖ បាទ! គាត់មិនបាច់មកជួបខ្ញុំទេ ដាក់កំណត់គេ ដាក់កំណត់ខ្ញុំហ្នឹង ខំទៅ ខ្ញុំស្រួលដែល ពួកនោះស្រឡាញ់ខ្ញុំណាស់... ខ្ញុំស៊ីបាយជាមួយគេដែរនោះ មិនដែលមកស៊ីបាយជាមួយ តាវ៉ាល់ បាយក្រប់ទុកដោយឡែកឯណា អត់ទេ បាយអត់បាយឃ្លានជាមួយគ្នាណា ។

ដានី ៖ ចុះកាលហ្នឹងយើងចាប់ផ្ដើមធ្វើការពីម៉ោងប៉ុន្មានទៅ?

មុត ៖ ម៉ោង ៧ បើទាំងវាស់នាយអាយទៅ ម៉ោង៨ យើងធ្វើ គាត់ប្រកាន់ទេ ភ្លឺឡើងយើងដឹងតែរៀបចំទៅ ទម្រាំតែវាស់វែងបានវាម៉ោង៧, ៨ ។

ដានី ៖ ដល់ពេលយើងបាយថ្ងៃម៉ោងប៉ុន្មាន?

មុត ៖ បាយថ្ងៃឡើងមកម៉ោង១១ បើប៉ះណាម៉ោង១១ជាង ពួកនោះសម្រុកថាបានពីព្រឹក នៅលើយើងដែរ គេដាក់នៅហ្នឹងស្រួលទេ ។

ដានី ៖ ប៉ុន្តែនៅក្នុងទីមួយៗគ្នាប៉ុន្មាននាក់ក៏ដោយ ដឹងតែវាស់អាម៉េចឲ្យបាន៣ម៉ែត្រគីប?

មុត ៖ បាទ! មួយក្រុម១០នាក់ៗ គ្នាក៏មិនហ៊ានសម្រេច អាកូនក្មេងនោះ ទាល់តែយើងដើរវាស់ឲ្យគ្នា ដូចយើងដាក់កម្លាំងប្រូគណាលោកគ្រូ ដូចខ្ញុំជម្រាបត្រង់ថានេះវ៉ើយមុខសញ្ញាអ្នកណា ក្រុមទី១ ទី២ ទី៣ អាក្រុមដាក់គ្នាមួយក្រុម អត់មានដាក់ដោយឡែកទេ ដូចខ្ញុំនៅក្ដាប់ជាប់តែម្ដង ។

ដានី ៖ ពូចាំមើលគេធ្វើ?

មុត ៖ អត់មានអង្គុយចាំមើលគេធ្វើទេខ្ញុំរែកប៉ះណា កម្លាំងខ្ញុំដែលមិនកាប់ ក៏នៅចាំជួយ ដូចថាខ្ញុំកម្លាំងរួមចល័ត ដូចថាជួយអ្នកនេះបន្តិច ជួយអ្នកនោះបន្តិច ខ្ញុំជួយរែកគេឡើងដែរ បន្តិមានរៀងខ្លួន ចបមានរៀងខ្លួន ប៉ុន្តែខ្ញុំមិនបានកំណត់៣ម៉ែត្រគីបខ្លួនខ្ញុំទេ ខ្ញុំទុកសម្រាប់ខ្ញុំវាស់ជួយវាស់ ជួយសម្រួលខ្ចបនេះខ្ញុំមិនបានដូចគេទេ ធ្វើមិនបានដូចគេទេ ។

ដានី ៖ ចុះអ្នកដែលឈឺ កម្លាំងដែលឈឺអីគេអត់វាស់បញ្ចូល ឬវាស់បញ្ចូលដែរ?

មុត ៖ កម្លាំងគ្នាទទ្រង់តទ្រម វាតាមធម្មតានេះតែលឺលក់ដែរ យកឲ្យតែគ្នាបានរួចដែរ ប៉ះអ្នកណាទៅដូចថាគ្នារាងមិនស្រួល មិនអីចឹង ក្តាប់មើលតាមចំណោមក្រុមនីមួយៗដែលគ្នារាងអន់ អន្តុយសំកុកអីច្រើនអី ខ្ញុំទៅសារ៉េអានោះដែរ ដើម្បីគ្នាបានរួច វាបានផុតទាំង អស់គ្នាដែរ ធ្វើការរាងយូបន្តិច ពួកកម្លាំងដូចគ្នានោះគេមិនជួយគ្នាទេ អ្នកណាដែលនៅយូនោះជួយគ្នាទៅឲ្យទ្វេរួច៣ម៉ែត្រគីប នឹងអាលឡើងទៅរកកូនកណ្តុរ រកក្តាមលូកកង្កែប លូកអី បានហូបឆ្អែត អន្ករបាយទឹកអីវារបបហ្នុងហើយ ម្នាក់មួយកំប៉ុងព្រឹក មួយកំប៉ុងល្ងាច ។

ដានី ៖ បាន មួយកំប៉ុងព្រឹក មួយកំប៉ុងល្ងាច?

មុត ៖ បាទ! អត់ដាច់ទេអន្កនោះ ។

ដានី ៖ អីចឹងក្នុងមួយម្នាក់បានមួយកំប៉ុង មួយកំប៉ុងល្ងាច?

មុត ៖ បាទ!

ដានី ៖ អីចឹងក្នុងមួយកងធំពូចាត់មានអ្នកចុងភៅអីដែរអត់?

មុត ៖ បាទ! មាន ។

ដានី ៖ ចុងភៅប៉ុន្មាននាក់?

មុត ៖ ចុងភៅ ២នាក់ ក្នុងម៉ាកងធំខ្ញុំចុងភៅ២នាក់ឆ្នាំងប៉ុនៗណេះ បាយ២ឆ្នាំង សម្ល២ឆ្នាំង ជួនណាគេមានអាត្រីកញ្ចុះក្រៀមត្រីអី ត្រីប្រមាត្រីអី កាលណុះត្រីប្រមាយើង អត់ទេលោកគ្រូ ហូបមិនអីទេ ។

ដានី ៖ ត្រីកញ្ចុះក្រៀមបានពីណាមក?

មុត ៖ បានមកពីនេះ បានមកពីខាងទន្លេ ខាងអាជីវកម្មគេ គេដឹកមកណា ខាងក្រោមមិនដឹង នៅខាងទន្លេហ្នឹងគេដឹងមក ។

ដានី ៖ កាលហ្នុង អីចឹងយើងហូបចុកអីអត់ខ្វះខាតទេ?

មុត ៖ បែបបងប្អូនខ្វះបែបគ្នាខ្វះអីចឹងហើយ តែខ្ញុំដូចមិនខ្វះអីទេ ហូបទៅដូចមិនមានអ្នកណាថាខ្វះ អីម្នាក់មួយចាប់គោមប៉ុនៗណេះ ។

ដានី ៖ អីចឹងយើងមានអ្នកទៅ...

មុត ៖ បើនៅជាមួយតាវ៉ាល អត់សូវយ៉ាប់ទេ បើអ្នកទៅពីសហករណ៍គ្នាយ៉ាងណាស់ បើនៅជាមួយចល័តតាវ៉ាលស្រួល ។

ដានី ៖ អូ! អ្នកដែលនៅជាមួយចល័តតំបន់អត់ពិបាកទេ?

មុត ៖ បាទ!

ដានី ៖ ពិបាកតែអ្នកនៅតាមចល័តសហករណ៍?

មុត ៖ បាទ! ពិបាកដែរលោកគ្រូ វាមិនមែនថាស្រួលទេ កុំនិយាយថាស្រួល បើយើង ធ្វើការរាល់ថ្ងៃឈឺល្មមៗយើង មិនហ៊ាននៅដែរ វាមានពេលស្រួលឯណា លំបាកមែន ក៏ប៉ុន្តែយើងបានស៊ីមធ្យម គ្នាចេះតែប្រឹងទៅ វាដូចគោដូចក្របី លោកគ្រូអើយទាំងគេ ទាំងខ្ញុំមិនដឹងថាងាប់ថ្ងៃណា សូម្បីតែខ្លួនយើង យើងមិនហ៊ានធានាថាខ្លួនយើងយ៉ាងណាផង ។

ដានី ៖ អ៊ីចឹងពេលដែលពូទៅជួបគាត់ ទៅរាយការណ៍ឲ្យគាត់រាល់ល្ងាចអ៊ីចឹង ដល់ពេលរាយការណ៍ហើយប្រជុំទៀត ឬអត់ទេ?

មុត ៖ ជួនទៅរាយការណ៍អត់ប្រជុំទេ ប៉ុនជួនណាមានផែនការអីក្រោយ ពីតំបន់ដាក់ចុះមកទៀតវាមានផែនការទៀត ចង់ចាត់កម្លាំងចេញទៅទប់ឯណាៗ ឆ្ងាយឯណាៗ ដាច់ឯណា មានផែនការទៀត អាហ្នឹងគិតគូរតាមហ្នឹងទៀត ប៉ះណាគេដកមួយកងធំ ឥឡូវគេថាគេត្រូវការម៉ាកងធំទីពា ឥឡូវដកម៉ាកងតូចទៅទប់ទល់ត្រង់ណោះត្រង់ណុះទៅ ខ្ញុំដកឲ្យទៅមួយកងតូចទៅ ៣០នាក់ទៅ ។

ដានី ៖ ដក៣០នាក់ទៅ ប៉ុនយើងដកម៉ែត្រតាមហ្នឹងទៀតទៅ?

មុត ៖ បាទ! គេទៅណុះគេមានផែនការផ្សេងដាច់ដោយឡែក ទោះបីគេធ្វើផ្សេងពីយើង អត់ដាក់ម៉ែត្រគីបក៏បាន ឲ្យតែបានដាច់ពីមួយទៅមួយរឿងផ្សេង អត់មានត្រូវតែមួយទេ ។

ដានី ៖ អ៊ីចឹងយើងធ្វើរាល់ថ្ងៃរហូត ពីថ្ងៃច័ន្ទ ដល់ថ្ងៃអាទិត្យម៉ង?

មុត ៖ អត់មានអាទិត្យទេ លោកគ្រូ រហូតរាល់តែថ្ងៃ អត់មានថាថ្ងៃណាទំនេរទេ អត់មានទេ ថ្ងៃទំនេរមិនមានទេឡើងរកថាថ្ងៃនេះអញទៅណាបានមិនមានទេ ទៅរាល់ថ្ងៃទាំងខ្ញុំ ទាំងគេ ទាំងអស់គ្នា ។

ដានី ៖ ចុះពេលបាយគេមានបន្លែមានអីដែរអត់?

មុត ៖ អត់មានទេលោកគ្រូ ប៉ះណាមានស្ករត្នោតយើងហ្នឹង គេយកទៅដាក់ឲ្យដែរ នាំចែកគ្នាលិត ទៅគ្មានបន្លែមទេ ។

ដានី ៖ ចុះទឹកអីយ៉ាងម៉េចដែរ?

មុត ៖ ទឹកក្រណាស់លោកគ្រូអើយ កាលសម័យខ្ញុំទឹកក្រណាស់ ទឹកឡើងខ្មៅ សឹងថាឡើងខេះ ដងមកដាំបាយឡើងក្រហម អាបាយណាលោកគ្រូ ទឹកវាល្អក់ទៀត........ ប៉ះណារហូតដងអាទឹកល្អក់គៀនត្រពាំងថ្នុផុងៗ និយាយបានត្រីស្លួ អត់ម្ហូបទេ ត្រី ពួកកម្លាំងខ្ញុំរកបានស៊ីត្រី ជំនួយក្រៅ

ត្រីអាំង ត្រីដុតប៉ុន នឹងៗ យកមកដួបផ្សំ ប៉ះណាឡើងមកទៅដងទឹកដីកៗ ទៅបានបន្ទំកាយទុកស៊ី ផ្នែកទៀត ពួកនោះរកស៊ីផ្សំស៊ីណាស់លោកគ្រូអើយ បានគេធ្វើបានផ្សំណាស់ៗ

ដានី ៖ ចុះកាលហ្នឹងយើងពេលទៅប្រជុំអី ពីព្រោះកាលហ្នឹងយើងមិនមានផែនការដូចថា យើងដូចជាអ្នកបេះ ដូចថាអ្នកប្រជាជនថ្មី ឬក៏ជាសមាសភាពដូចជាគាត់ជាទាហាន ឬក៏គាត់ជានិស្សិត ឬក៏រាជការអី កាលហ្នឹងគេប្រជុំអី គាវ៉ាល់អីគាត់ដាក់ផែនការយ៉ាងម៉េចទៅ?

មុត ៖ បាទ! គេអត់សួរសួរយើងប៉ុន្មានទេ ដូចថាក្រោយមកទៀត បើសិនជាអ្នកណាមានសកម្មភាពអី អាហ្នឹងគេហៅយើងទៅសួរដោយផ្ទាល់ បើយើងមានការសង្ស័យពី“ក” ឬ“ខ”អីមួយណាស់ៗ ប៉ះណាំ គាត់ឲ្យយើងហៅទៅឲ្យគាត់សួរផ្ទាល់ សំងាត់ដែរៗ

ដានី ៖ ហៅអ្នកហ្នឹងទៅសួរ?

មុត ៖ បាទ! ហៅទៅសួរ ហៅឲ្យទៅជួបផ្ទះ គ្នាភ័យហើយតែពួតែហៅទៅនោះ ដឹងតែបានម៉ោវិញៗ ដូចកងខ្ញុំ ឃើញហៅទៅ២នាក់ដែរ ដូចមិនឃើញអីទេ ឃើញម៉ោវិញមិនដឹងឆ្លើយយ៉ាងណា ព្រោះខ្ញុំប្រាប់ បើគេសង្ស័យថាធ្វើការនៅសម័យសាធារណៈរដ្ឋលន់ នល់ នេះ សក្តិប៉ុននេះ សក្តិប៉ុណ្ណោះ ឬមាឌ មើលមាឌមើលរៀងរ៉ៅយើងនោះណាៗ ថាគាត់ធ្វើការអី គាត់ថាខ្ញុំប្រាប់ ខ្ញុំមិនហ៊ានប្រាប់ដែរ ពួកនេះកុំនិយាយប្រាប់ថាយ៉ាងណាយ៉ាងណែនោះៗ ប្រសិនជាគេសួរពីរឿងថាធ្វើអី? ថាចង់ធ្វើអីខ្លះ? ខ្ញុំថាខ្ញុំអត់ចង់ធ្វើអីទេ ស្រេចតែអង្គការចាត់តាំង ព្រោះអង្គការតម្រូវខ្ញុំទៅកន្លែងណា ខ្ញុំធ្វើកន្លែងនោះ ខ្ញុំអត់មានគ្មានទាមទារកល័ក្ខខ័ណ្ឌអ៊ីទាំងអស់ ខ្ញុំប្រាប់ទោះបីខ្លួនឯងបេះអីក៏ដោយ ខ្ញុំមិនបានសួរលកខ្លួនឯងទេ បើដឹងថាខ្លួនឯងបេះ កុំនិយាយថាខ្ញុំថ្នាក់ទីប៉ុននេះខ្លាចគេលកយើងៗ តាមពិតគេសួរតាមនឹងច្រើនៗ

ដានី ៖ អញ្ចឹងក្នុងកងពូ អត់មានត្រូវបានគេចាប់ ឬបាត់ខ្លួនទេ?

មុត ៖ មានៗ កងខ្ញុំអត់មានទេ វាព្រោះមានកងគេផ្សេងៗមានគេហៅទៅរៀនដែរ ក៏ប៉ុន្តែអត់មានរឿងដឹសផុសតាមនោះអត់មានទេៗ

ដានី ៖ អត់មានទេ?

មុត ៖ បើថាគេហៅថាទៅធ្វើការនោះ គេដកយកទៅ គេទៅលើទៅ ដឹងគេដកយកទៅត្រង់ណាៗ

ដានី ៖ អញ្ចឹងគេដកទៅបាត់ៗទៅ អត់មានឃើញគេចាប់ គេធ្វើទារុណ រឿងអីទេ?

មុត ៖ បាទ! អត់រឿងដឹសផុស ឲ្យពិបាករំខានចិត្ត នៅពីមុខមាត់យើង អត់មានទេៗ

ដានី ៖ ចុះអត់មានកន្លែងមន្ទីរឃុំឃាំងនៅក្បែរហ្នឹងទេ?

មុត ៖ អត់មានទេ ។

ដានី ៖ អត់មានទេ?

មុត ៖ អត់មានទេ បាទ! ។

ដានី ៖ ចុះកងពួជដូចថាពួកគាត់ធ្វើការហ្នឹង មានឈឺមានអីដែរ ឬអត់?

មុត ៖ មាន! លោកគ្រូ ។

ដានី ៖ មានឈឺ?

មុត ៖ មានឈឺ មានថ្នាំពេទ្យលេបធម្មតា ថ្នាំៗសម័យយើងដែល មិនមានថ្នាំសូន្យថ្នាំអីទេ មានបើថ្នាំកម្ទាំង ថ្នាំគ្រាប់ក្រហមកម្ទាំង វីតាមីនបេកំភ្លិចអីទៅណា៎ ថ្នាំកម្ទាំងលេប ។ ថ្នាំកាលនោះមានប៉ារ៉ាអាលេខ៣០០ ។

ដានី ៖ ប៉ារ៉ាលេខ៣០០?

មុត ៖ បាទ! មានពេទ្យមានអីចុះតាមកង ដូចទ័ពពួកហ្នឹង ក្រោយមកទៀត គេបង្កមេទៅជាទ័ពហើយ ។ លោកហ៊ីង មានផែនការក្រឡាប់បន្ទាន់ហ្នឹង មានផែនការ ក្រោយពីដឹកសំភារៈសំបើមបុកកន្លែងពួកកងចល័តនោះឯង ។ ដល់ក្រោយមកទៀត លោកគ្រូ វាមានដូចថាចោមនៅមួយ តែពេលនេះវាខោអាវខ្មៅទាំងអស់មើលទៅស្អាត ។ មើលទៅក៏ដូចថាយើងបំពាក់អាវុធទៅក៏ទ័ពបាត់ទៅហើយ ។ ខោអាវមកបើកដឹកមកម្នាក់ម៉ាកំប្លេរ ក្រមាមួយ ខោម៉ាសម្រាប់ ក្រមាមួយៗទាំងគេ ទាំងឯង ។

ដានី ៖ ប៉ុន្តែលោកពូកាលហ្នឹង គ្រប់ក្នុងកងរបស់ពូ ម្នាក់គឺត្រូវតែ៣ម៉ែត្រគីប?

មុត ៖ ៣ម៉ែត្រគីប ។

ដានី ៖ អត់មានអ្នកណា តិចជាង៣ម៉ែត្រគីបទេ?

មុត ៖ អត់មានទេ ។

ដានី ៖ អត់មានកម្ទាំងទី១ ទី២ ៣ម៉ែត្រគីប៣ កម្ទាំងទី៣អី?

មុត ៖ បាទ! ៣ម៉ែត្រគីបស្មើគ្នាឈឹង ។

ដានី ៖ ស្មើឈឹងម៉ង?

មុត ៖ បាទ! មិនថាឈឺមិនថាអីទេ គឺ៣ម៉ែត្រគីបស្មើតែម្តង បាទ! ។

ដានី ៖ ស្មើទាំងអស់ម៉ង?

មុត ៖ បាទ! ស្មើទាំងអស់ ។

ដានី ៖ តាំងពីចាប់ផ្តើមរហូតដល់ចប់?

មុត ៖ ព្រឹកឡើងទៅវាស់កាប់៣ម៉ែត្រគីប ដាក់កម្លាំងបណ្ដោយ វែកកម្លាំងពីកងធំ ដាប់គ្នារអឿនចេះ លោកគ្រូ ពីកងធំទី១ ទី២ ទី៣ ខ្ញុំក៏រំលែកតាម ក្រុមទី១ ទី២ ទី៣ដូចគ្នាដែរ ។ ដផ្លូវគ្នាចេះ ម៉ាចំហៀងខាងនោះ ម៉ាចំហៀងទាំងអស់គ្នា ខាងនេះទាំងអស់គ្នាធ្វើបន្តគ្នារាយតាម កងដូច យើងរាយខ្សែត្រៀម ។ បាទ! របៀបដូចធ្វើរាយខ្សែត្រៀម ។

ដានី ៖ ដូចរាយខ្សែត្រៀម?

មុត ៖ ដូចរាយខ្សែត្រៀមជីកតែម្ដង វែកដូច រាយខ្សែត្រៀមជីក បាទ! ។

ដានី ៖ ចុះពូមានដែលធ្លាប់បានឡើងទៅរៀននៅមន្ទីរតំបន់អី ឬក៏ទៅភូមិភាគនៅខាងបាត់ដំបង?

មុត ៖ បាទ! កាលនោះគេត្រៀមៗឡើងចូលបក្សគេដែរ លោកគ្រូ ប៉ុន្តែអត់មានដែលបានឡើងទៅរៀន ខ្ញុំទើបនឹងចូល កាលវាគេចាប់មេ ដូចថាវាបែកបាក់ដែរ ។

ដានី ៖ បាទ! ចុះពូកាលពេលយើងប្រជុំអី ឡើងម៉ោមន្ទីរតំបន់ដែរ?

មុត ៖ បាទ! ទេ ខ្ញុំប្រជុំធំ គឺថាដល់មានផែនការអត់ដែលបានឡើងម៉ោស្វាយ ម៉ោអីទេ ត្រឹមកងអនុសេនាធំ គឺថាបន(កន្លែង) ប្រជុំធំកន្លែងតាវ៉ាល់តែម្ដង ។

ដានី ៖ កន្លែងតាវ៉ាល់?

មុត ៖ ក្រោយមកទៀត កាលមានការមមារញឹក ចង់ផ្លាស់ប្ដូរ ម៉ោង២ប្រជុំក៏មាន ត្រឹមមេវរៈ ។

ដានី ៖ ម៉ោង២យប់?

មុត ៖ បាទ! ត្រឹមមេវរៈៗ តាសនៗងាប់ហើយ តាសន ។

ដានី ៖ អញ្ចឹងលោកពូនៅក្នុងកងចល័តតំបន់ហ្នឹង យើងកងអនុសេនាធំហ្នឹង មានៗវរៈអីទៀតឬអត់?

មុត ៖ មានវរៈពួកតាសន មានវរៈបន្ទាប់ពីតាវ៉ាល់ មានតាសនក្ដាប់រួមពីពួកកងអាធំគេមាន ប្រធានវរៈ ។

ដានី ៖ អូ! ប្រធានវរៈ?

មុត ៖ ប្រធានវរៈសេនាធំ ក្ដាប់រួមតែម្ដង តាសន ។

ដានី ៖ អានឹងប្រធានវរៈសេនាធំ?

មុត ៖ បាទ! ប្រធានក្ដាប់រួមទាំងអស់ ទាំង៣កងធំនេះ កងធំទី១ ទី២ ទី៣នេះ តាសនគាត់ក្ដាប់ទាំងអស់ ។

ដានី ៖ ចុះអាហ្នឹង កងបុរស?

មុត ៖ បាទ!

ដានី ៖ ចុះខាងនារី?

មុត ៖ ខាងនារីដូចគ្នាបងមិត្ត ។

ដានី ៖ បងមិត្ត?

មុត ៖ បងមិត្តនៅចារគោកទេ អូ!នែក!ស្ពានស្រែងដូចខ្ញុំថា បៀតស្រុកជាមួយចែគិន ប្រពន្ធតាវ៉ាល់ ហ្នឹងឯង គាត់អ្នកគៀរ តំបន់ចាស់ គាត់វ័យចាស់ហើយប្រហែលជាខ្ទង់៤០ជាងហើយ ដែលនៅជាមួយខ្ញុំ ។

ដានី ៖ កាលនឹងវរៈសេនាតូច ហើយវរៈសេនាធំ?

មុត ៖ វរៈសេនាធំ ក្តាប់រួមទាំងពាកងដូចគ្នា បាទ! វរៈសេនាធំ ។

ដានី ៖ ទៅបាន តាវ៉ាល់ គាត់ធ្វើប្រធាន?

មុត ៖ តាវ៉ាល់ក្តាប់រួមពីលើពួកនេះទៅទៀត ។

ដានី ៖ បានតាវ៉ាល់ម្នាក់ អត់មានអ្នកណា?

មុត ៖ ចប់ត្រឹមតាវ៉ាល់ អត់មានអ្នកណាមកញៀវញៀវទេ ។

ដានី ៖ អត់មានអនុអីគាត់ទៀតទេ?

មុត ៖ យោធាណាក៏មិនមានដាក់ម៉ាគ្រាប់ទេ មានតែតាវ៉ាល់មួយគត់ បាទ!អត់មាន ទេ ។

ដានី ៖ ចុះពេលប្រជុំធំអី តាហ៊ីងអីគាត់មកប្រជុំទេ តាហ៊ីង តាជៀលអី?

មុត ៖ តាហ៊ីងមានចូលរួមខ្លះ បាទ!ទាល់អត់មានមមាញឹកប៉ុន្មានទេ ទាល់តែមានការធំដុំ ។

ដានី ៖ ទាល់តែមានការធំដុំ?

មុត ៖ បាទ!

ដានី ៖ បាទ! ចុះតាជៀល?

មុត ៖ តាជៀល បើមកៗជាមួយតាហ៊ីង ឡានហ្សីពអាជីម៉ោជាមួយគាត់ ។

ដានី ៖ ជិះមកជាមួយគ្នា?

មុត ៖ បាទ! សាច់ការ មកៗគាត់និយាយលេងតាមធម្មតា សើចជាមួយនារីអីធម្មតា ដូចមិនមាន ការអីមកក្នុង ។

ដានី ៖ ចុះតាញឹម គាត់ដែលម៉ោ?

មុត ៖ តាញឹមមៅៗអត់ចុះពីឡានអាហ្សីពអាជី ។

ដានី ៖ អត់ចុះ?

មុត ៈ បាទ!

ដានី ៈ គាត់ម៉ោអត់ចុះពីឡានទេ គាត់ម៉ោធ្វើអី?

មុត ៈ ម៉ោ ដើរយ៉ាងណាចុះមកកន្លែងតាវ៉ាល់តិច អត់សូវដើរមើលតាម ត្រង់នេះត្រង់នោះអីពេលណាទំនេរ ។ តាជៀលថាឲ្យគាត់ម៉ោៗតាហ៊ីង ឲ្យពួកតំបន់ៗមក មានតែភាគ ឆ្កក៤-៥នាក់ឆ្កបវា ។

ដានី ៈ គាត់ខស្សរាហ៍ម៉ោ ហើយក៏មិនដែរ?

មុត ៈ ខស្សរាហ៍ម៉ោមានផែនការ ក្រោយទៀតម៉ោយប់ ម៉ោថ្ងៃ មាយប់ ល្ងាចប៉ះណាម៉ោងម៉ោ២យប់ក៏មានមក ។

ដានី ៈ គាត់ម៉ោធ្វើអី?

មុត ៈ ដឹកទ្រនាប់ជើង ទ្រនាប់ជើងកម្ពុជាខាងជើងបូព៌ានោះម៉ោ ចែកពួកចល័ត ។

ដានី ៈ អ្ហូ! ដឹកទ្រនាប់ជើង?

មុត ៈ ទ្រនាប់ជើងល្អៗដើរចែក ។ កាលនោះមានផែនការហើយលោកគ្រូ ទាល់តែផែនការនោះ ខ្ញុំភ័យដែរ ។

ដានី ៈ ផែនការម៉េច?

មុត ៈ ដល់តាវ៉ាល់គាត់និយាយការធ្វើការ គាត់និយាយផងបើកកន្សែង បើកដែកកេះ បើកអាវឃឹត-សក្វាន់ ឲ្យពួកមេៗណា៎ ។ បើករួចគាត់និយាយថា ពួកមិត្តឯងនេះ សុទ្ធតែសក្តិ៣ គាត់និយាយនោះ ពួកមិត្តឯងសុទ្ធតែសក្តិ៣ សក្តិ៥ គាត់ចង្អុលចុះដំណើរកំប្លែងលេងជាមួយយើង ប្រជុំរួច ។ គាត់ប្រដូចទៅយ៉ាងណាដូចចង់ចងក្រងជ្រើសរើសឲ្យទៅឲ្យកងចល័តនេះ វាក្លាយទៅជាទ័ពស៊ីក៏មិនដឹង ។ វាផែនការ មានផែនការត្រូវនៅភ្នំកូនខ្វែងនោះឯង ។ ផែនការដែលរើបំរាស់មិនរួច ខ្ញុំដឹងមិនដល់មានផែនការមានហើយ ។ ប្រជុំរៀបស្អុំស្រែក្រ អត់មានប្រជុំរើចោលទេ បើរឿងប្រជុំមានគ្រោងការបំពាក់សំភារៈអីឲ្យទៅ តែគេលាក់ការណ៍ដែរ ។

ដានី ៈ ឆ្នាំណាអាហ្នឹង?

មុត ៈ ឆ្នាំអាចុងហយនេះ បែបចុងឆ្នាំ៧៧ ។

ដានី ៈ មានផែនការ?

មុត ៖ ទាល់តែមានផែនការចង់បំពាក់អាវុធពួកកងចល័តហ្នឹងឯង ក៏ប៉ុន្តែអត់ទាន់ធ្វើទៅរួច ប៉ុនសម្ភារៈដឹកមកអស់ៗ តែទាំងវែង ឆ្ងាយដល់ពេលអាដំណើរការគេទៅណា យើងដឹងមិនដល់និយាយមិនកើត វាច្បាស់លាស់ យើងនិយាយធ្វើអីៗ

ដានី ៖ បាទ! ចឹងដល់ពេលមានផែនការ បងបំពាក់អាវុធហើយម៉េចទៀតទៅ?

មុត ៖ ដែលមានបំពាក់ ក៏ប៉ុន្តែអត់មានបានបំពាក់ផង ផែនការនោះក៏វារលាយសូន្យឆឹងទៅ ចាប់អ្នកនេះ ចាប់អ្នកនោះទៅក៏វាខ្សឹបស្ងាត់ៗ

ដានី ៖ ចាប់ពីណា?

មុត ៖ កាលនោះចាប់តាហ៊ីង ចាប់តាវ៉ាល់ បាទ! ចាប់ទៅអស់បាត់ៗ

ដានី ៖ តែមុននឹងចាប់មានខាងណាគេមក?

មុត ៖ ចាប់ឆ្នាំនិរតីគេចុះមក ខាងនិរតីៗ គេហៅនិរតីៗមកពីខាងណាលោកគ្រូ?

ដានី ៖ ខាងតាកែវ ខាងអី?

មុត ៖ ខាងតាកែវ នេះឯងខាងនិរតី គេចុះមកចាប់ពួកពាយ័ព្យៗ

ដានី ៖ តែនិរតីចុះមកនឹងមុនមានផែនការប្រជុំនឹង ហើយក៏ចុះមកក្រោយ?

មុត ៖ ចាប់មកមុន ដែលប្រជុំមុនៗនិរតីចុះៗៗ ឡើងយូរគ្រាន់ហើយបានប្រជុំសារចុះសារ ឡើងមិនទាន់រៀបដើងព្រួលអីបានល្អទេ បាននិរតីចុះមកចាប់ គាត់មានផែនការដូចថា បែកការណ៍អីចាប់ៗ

ដានី ៖ និរតីគេចុះមកគេធ្វើអី?

មុត ៖ និរតីចុះមកមានប្រុសមានស្រី មានយោធាទៀតៗ ដល់មានយោធាទៅ មានយោធាចុះមកនៅតាមមុខសញ្ញាយើងនេះឯង ប៉ុន្តែចុះមកស៊ើបសួរបងប្អូនយើងស៊ីឆ្អែត ស៊ី មិនឆ្អែតអត់ឃ្លានៗ អ្នកណាក៏យ៉ាប់យឺន ប៉ះណាវាយការណ៍ទៅមេចេះចុះទៅណា និរតីចាប់ៗ

ដានី ៖ អូ! ចឹងកាលពេលនឹង ដូចថាពេលនឹងនិរតីចុះមកដូចថាមានគេធ្វើការជាមួយតាវ៉ាល់ តាហ៊ីងអីអត់ទេ?

មុត ៖ អត់មានទេ ក៏ប៉ុន្តែគេអត់បានមកនៅរួមជាមួយទេ ដូចថាគេមកម៉ាចផ្តោមគេ គេនៅត្រង់ណាគ្រាន់ថា ពួកនោះបើរបៀបមកតាមខ្ញុំពិនិត្យទៅដូចចារកិច្ចចេះឯងមកដូចថា មកយកការណ៍នៅក្នុងកងតែនឹងម្តងមកៗ

ដានី ៖ មកធ្វើការដែរអត់ទេ?

មុត ៖ អត់បានធ្វើការទេ បើមានដើរសួរពាស់ណាពាស់ណៃមាន ដើរសួរកន្លែងគេមាន យោធាមានអីមករកការនឹងចាប់ហើយ តែមិនដែលគេដើរលក(លប)សួរមើលសិន ។ មកចាប់តែម្តងតែអត់មកប្រាប់ទេ ។

ដានី ៖ ចុះពេលគេចាប់តាវ៉ាល់អី ពូឃើញទេ គេចាប់?

មុត ៖ បាទ?

ដានី ៖ តាវ៉ាល់?

មុត ៖ ខ្ញុំអត់បានឃើញ ឃើញនៅកន្លែង ខ្ញុំនៅកន្លែងការងារៗទៅអត់ដឹងគេចាប់កន្លែង មានយោធាគេចាប់អីខ្លះ ។

ដានី ៖ តាវ៉ាល់គេចាប់ដែរ?

មុត ៖ បាទ! គេចាប់យកទៅ ។

ដានី ៖ ចុះតាមោងអី?

មុត ៖ តាមោងគាត់នៅខាងស្រុក គាត់មិនបានចុះដាប់ជាមួយតាវ៉ាល់ម្តងណា គាត់នៅប្រចាំនឹងស្រុកព្រះនេត្រព្រះយើង ។

ដានី ៖ ប្រចាំស្រុកព្រះនេត្រព្រះ?

មុត ៖ បាទ! សាលាស្រុកផ្ទះគាត់ ។

ដានី ៖ ចុះតាហ៊ីង?

មុត ៖ តាហ៊ីង ក៏ខ្ញុំមិនបានដឹង គេចាប់ឯងផ្ទះគាត់ដែរ គាត់នៅតំបន់នេះ ខ្ញុំនៅត្រពាំងថ្ម នេះ ។

ដានី ៖ ចុះតាវ៉ាល់គេចាប់ទៅ ពូចាំ គេចាប់អាចខែណាដែរ ចេញឆ្នាំ ចាប់ឆ្នាំណា?

មុត ៖ តាវ៉ាល់ចាប់នៅឆ្នាំ៧០ ដើមឆ្នាំ៧៦ ៧៧លោកគ្រូ វ៉ាវៗនឹងឯង ។

ដានី ៖ ហ៎! ដើមឆ្នាំ៧៧ ក្រែងពូថាគេទើបចាប់ផ្តើមធ្វើទំនប់តើ?

មុត ៖ ទេ! វ៉ាវៗនៅក្នុងឆ្នាំ៧៧ៗនឹងលោកគ្រូ ប៉ុនមិនដឹងថាវាចុងខែ ឬមួយវាជិតដាច់ទៀត ក៏មិនដឹងផង ។

ដានី ៖ ចឹងគេចាប់តាវ៉ាល់មុនចាប់តាហ៊ីង ហើយចាប់ពីណាមុន?

មុត ៖ បើនិយាយពីរឿងចាប់ៗខាងតំបន់នេះឯងមុន ពួកតាវ៉ាល់ តាមោង អូ!នែក!តាជៀលអីនេះមុនហើយ ទុកឯងនេះមុនបានតាវ៉ាល់នឹងក្រោយ ។

ដានី ៖ បាទ! ហើយបានគេចាប់តាវ៉ាល់អីទៀត?

មុត ៖ ចាប់តាវ៉ាល់ទៀត ។

ដានី ៖ ចាប់ហើយគេមានតែងតាំងថ្មីទៀត ពួកនិរតីមក?

មុត ៖ ចាប់ តែងតាំងដែលអស់ពីតាវ៉ាល់ តាសនទៅ តាសននោះគាត់នៅក្តាប់រួមអាកងអនុសេនាធំ ខ្ញុំ កងវរៈក្តាប់រួមពួកយុវជនប៉ុន្មាន ទាំងនារី ។ មានតាសន មានយាយមិត្តមួយ ស្រីមួយ ប្រុសមួយ ក្តាប់រួមទាំងនារី ទាំងប្រុស ។ តាសនក្តាប់ទាំងស្រីទាំង ប្រុសដូចគ្នា ។

ដានី ៖ ដល់ចឹងគេចាប់តាសន ចុះយាយមិត្ត?

មុត ៖ តាសន គេចាប់ផ្លូវទៅត្រពាំងថ្មនោះឯង កប់អន្លុយទេ តាសន ។

ដានី ៖ កប់អន្លុយ?

មុត ៖ បាទ! និរតីមកចាប់ ជីកអន្លង់សន្ទុះ ដូចយើងសន្ទុះសសរចេះ អត់បានដេកបានអី តាសន បាទ! ចាប់មកពីអាងត្រពាំងថ្មនេះឯង អាងត្រពាំងថ្ម ។

ដានី ៖ ចាប់គាត់កំពុងធ្វើអី?

មុត ៖ ចាប់គាត់កំពុងមើលគេជីកទំនប់ដែរ ។

ដានី ៖ ចឹងចាប់គាត់យកទៅណា?

មុត ៖ ចាប់យកមកក្រោយពេល ព្ញត៌មានថា អត់បានយកទៅដាក់គុកដាក់ច្រវ៉ាក់ជីកមក ស្វាយជីកមកអីទេ ។ កាលយកឡានមកយកថា ជីកឡានហ្សីពទៅយក ថាយកទៅរៀន ដល់នេះព្យអត់បានទៅណា ថានៅនឹងចុងប៉ោយស្នួល គេហៅគោកក្រសាំង ។

ដានី ៖ គោកក្រសាំង?

មុត ៖ គោកក្រសាំង ប៉ោយត្រាច ។

ដានី ៖ គេយកធ្វើអីទៅ?

មុត ៖ ថាយកទៅសម្លាប់ចោលនឹងឯង ។

ដានី ៖ សម្លាប់ចោលនៅនឹង?

មុត ៖ សម្លាប់ចោលនឹងចុងគោកត្រាច់ ចេញមកពីប៉ោយស្នួលត្រពាំងថ្មនឹង ។

ដានី ៖ កប់គាត់ដូចអន្លុយម៉េច?

មុត ៖ កប់អន្លង់ ព្យគេថា អូ!អាកប់គ្នាអត់កប់អន្លង់ដូចយើងសន្ទុះសសរ កប់អន្លុយ ។

ដានី ៖ ទម្លាក់ចូលក្នុងរណ្តៅ ឬក៏?

មុត ៖ គេជីករណ្តៅ រួចទៅក៏ គេថាទម្លាក់ឈរកប់បណ្តោយ នេះសសរ ។ អត់ពីតាវ៉ាល់ដែល គេចាប់ ទៅ ត្រូវតែងតាំងតាញ៉ាវ ឈ្មោះ ញ៉ាវ ។

ដានី ៖ តាញ៉ាវហ្នឹង?

មុត ៖ ខ្ញុំរស់នៅជាមួយតាញ៉ាវ ម៉ាជាន់ទៀត ។

ដានី ៖ តាញ៉ាវនឹងមកពីណាមក?

មុត ៖ តាញ៉ាវមិនដឹងមកពីណាទេ មនុស្សនោះ ។

ដានី ៖ អ្នកនិរតី ហើយក៏អ្នកនៅក្នុង?

មុត ៖ អត់មាននិរតីទេ តាញ៉ាវឡើងកាន់ការអស់ម៉ារយៈពេល៤-៥ខែនោះលោកគ្រូបានបាត់តាញ៉ាវទៀត ។

ដានី ៖ ឡើងតាញ៉ាវ?

មុត ៖ បាទ!

ដានី ៖ ប្រហែល៤ខែ?

មុត ៖ បាទ! គេត្រូវចាប់តាញ៉ាវទៀត ។

ដានី ៖ ទៅឡើងពីណាវិញទៅ?

មុត ៖ ចាប់ពីចាប់តាញ៉ាវទៅ ក៏បែកបាក់ ដូចមិនមានតែងតាំងទេ ពេលនោះចល័តក៏ចាប់ផ្ដើមបែកខ្ញែកគ្នា ។

ដានី ៖ ចឹងកាលនឹងពេលដែលចាប់តាវ៉ាល់ទៅ ឡើងបាន៤ខែ គេចាប់តាញ៉ាវ ទៀត?

មុត ៖ បាទ! ចាប់តាញ៉ាវទៀត ។

ដានី ៖ តាញ៉ាវនឹង អ្នកស្រុកខាងពាយ័ព្យយើងដែរ ឬក៏?

មុត ៖ នៅខាងពាយ័ព្យៗ ។

ដានី ៖ ចុះកាលពេលគេចាប់តាហ៊ីង តាអីទៅ គេតែងតាំងពីណា?

មុត ៖ តាហ៊ីង ខ្ញុំអត់ដឹង តាហ៊ីងព្រោះបន(កន្លែង)សំងាត់គេនៅខេត្តនេះ បើយើងនៅតាមមុខព្រួញអត់ដឹងដល់ទេ ។

ដានី ៖ ចឹងពេលគេចាប់តាហ៊ីងទៅ ខាងនិរតីគេមក ដំឡើងហើយអត់ទេ?

មុត ៖ ដឹងនិរតីគេឡើង បើតាស្រុកៗព្រះនេត្រព្រះនេះ អស់ពីតាមោងទៅ មានយាយថែង ។

ដានី ៖ អូ!

មុត ៖ បាទ! ចៅហ្វាយស្រុកស្រី ។

ដានី ៖ អូ! ចឹងផុតពីតាមោងទៅគេដាក់យាយថែម?

មុត ៖ បាទៗ ផុតពីតាមោងមានយាយថែង ចៅហ្វាយស្រុក ។

ដានី ៖ យាយថែមគាត់មានដែលទៅត្រពាំងថ្មទេ?

មុត ៖ យាយថែមអត់ដែលបានទៅបង អត់ដែលបានទៅត្រពាំងថ្មទេ ។

ដានី ៖ អូ! អត់ដែលទៅ ។

មុត ៖ ទៅតែទំនប់ព្រែកជីកស្ពានស្រែង យាយថែមទៅៗមើលពួកខ្ញុំជីក ។

ដានី ៖ ចឹងពូពេលដែលគេចាប់តាវ៉ាល់ទៅ ពូនៅតែជា?

មុត ៖ បាទ! ខ្ញុំនៅធម្មតា ពេលនឹងខ្ញុំនៅក្នុងតែងគោលដែរលោកគ្រូ តែវាមានមេ ដល់ក្រោយដែរ មេខ្ញុំរៀនខ្លាចដែរ ខ្លាចប៉ុញ៉ាវ ។ តាញ៉ាវ រៀនគ្រនេម គ្រនើមមិនសូវនិយាយដែរ ។ ខ្ញុំខ្លាច ប៉ុញ៉ាវ មែនទែន អត់ពីតាវ៉ាល់ទៅ ។

ដានី ៖ អត់ពីតាវ៉ាល់ទៅ ខ្លាចតាញ៉ាវ?

មុត ៖ ខ្លាចតាញ៉ាវៗ ខ្ញុំមិនសូវទុកចិត្ត ។

ដានី ៖ ប៉ុន្តែយើងត្រូវរាយការណ៍ឲ្យតាញ៉ាវនឹង រាល់ថ្ងៃដែរ?

មុត ៖ រឿងស្អីៗខ្ញុំរាយការណ៍នៅបន(កន្លែង)តាវ៉ាល់នឹងឯង ផ្ទះគាត់ រោងគាត់ ។

ដានី ៖ អូ! គាត់នៅរោងនឹងដែរ?

មុត ៖ គាត់នៅរោងនឹង ។

ដានី ៖ នៅកន្លែងនឹងដែរ?

មុត ៖ បាទ!

ដានី ៖ តែយើងត្រូវរាយការណ៍ម៉ាថ្ងៃបានប៉ុន្មានម៉ែត្រគីបៗ ត្រូវរាយការណ៍ឲ្យតា ញ៉ាវនឹង?

មុត ៖ បាទៗ ។

ដានី ៖ តែតាញ៉ាវគាត់មានឲ្យយោបល់អី គាត់និយាយម៉េចដែរ?

មុត ៖ តាញ៉ាវមិនដែលមានឲ្យយោបល់ទេ មានប្រជុំយើងតាមធម្មតា ទិតៀន ស្វ័យ ទិតៀន ហើយនឹងរកការកសាងឲ្យរីកចំរើន មហាលោតផ្លោះ មហាអស្ចារ្យ របស់គេ លោកគ្រូ ។

ដានី ៖ ចុះកាលជំនាន់តាវ៉ាល់ គាត់មានថាឲ្យ មហាលោតផ្លោះ មហាអស្ចារ្យ រីក ចំរើន?

មុត ៖ មហាអស្ចារ្យដូចគ្នា មហាលោតផ្លោះដូចគ្នា ប៉ុន្តែតាវ៉ាល់ចាប់ពីត្រឹមស្ពង តាវ៉ាល់មិនទាន់រួច ស្ពានទី២ ស្ពងល្អិតជង ខ្ញុំបានទាន់តាញ៉ាវទៅបន្តវេណពី តាវ៉ាល់ ដែលក្តោបក្តាប់នៅខាង នោះ មិនទាន់បានរួចស្រួលបួលទេ ។

ដានី ៖ ប៉ុន្តែកាលនឹងគេចាប់តែមេធំៗទេ ដូចជាកងអនុសេនាធំអីនឹង គេអត់មានចាប់ ទេ?

មុត ៖ បាទ!កងអនុសេនាធំ ប្រុសគ្នាខ្ញុំរត់ពីកង ។ បាទ!រត់ម៉ាកងទី១ ៗកងខ្លាំងណាស់ មេតែរត់ហើយ គ្នា កិនេះសង់(ចំណេះដឹង) មេកងនោះខ្ពស់ផង ពូវិតនោះ មហាវិទ្យាល័យពុទ្ធិក រៀននៅភ្នំពេញ ពីដើមមិញ ។ គាត់អ្នកស្រុកដូនជ្រែង ។

ដានី ៖ អឺ! ឈ្មោះ វិត?

មុត ៖ វិត ។

ដានី ៖ ហ្នឹងគាត់រត់?

មុត ៖ បាទ!

ដានី ៖ រត់ទៅបាត់រហូត?

មុត ៖ បាទ! គាត់រៀនបានខ្ពស់ គាត់ភ្ញាក់ផ្អើលនឹងនិរតីមក គាត់សុខចិត្តរត់ៗទៅអត់រូបខ្លួនដែរ ទៅ ជាប់នៅភូមិកំបោរ គោករមៀតនោះ ចូលខ្មែរគ្រៀមគេនោះ ងាប់អស់ម៉ាចង្កោមគាត់នោះ ប្រហែល៤-១៥នាក់ មនុស្សកំពុងវ័យ៣០ ជាងអាយុ ។ ពួកតាវ៉ុយ, តាផាត់, ពួកសម្បត្តិ ។

ដានី ៖ តែពួកតាវ៉ុយ, តាផាត់, តាសម្បត្តិ?

មុត ៖ បាទៗ ស្លាប់ ។

ដានី ៖ ប៉ុន្តែកាលនោះ ពូអត់រត់នឹងគេ?

មុត ៖ ខ្ញុំដូចកាលនោះខ្ញុំនៅក្មេង ដូចខ្ញុំអាងថាដូចជាមិនអី ដូចថាមិនដែលមានអ្នកណា និយាយអី ក្នុងកងខ្ញុំក៏ស្ងាត់ស្ងៀមស្រួលទៅ ។

ដានី ៖ តែពូនៅធ្វើប្រធានកងដដែល?

មុត ៖ បាទ! នៅតែធម្មតាៗ ប៉ុន្តែខ្ញុំនៅមិនដែលមានអ្នកណាចាក់ចុចរឿងអីទេ ដូចខ្ញុំធម្មតាផង បែប ជាគេមិនស្អប់ខ្ញុំទេដឹងមកធ្វើដូចគ្នា ។ យើងដូចថា យើងមិនវៃប្រកពាអីទេ បើសិនវៃប្រកពាដូច ពួកនោះ ព្រោះពួកវិតមានការគំរាមកំហែងគេដែលនឹង បើ ។

ដានី ៖ តាវិត?

មុត ៖ តាវិត ទី១នោះខ្លាំងណាស់ ។

ដានី ៖ ចុះទី២ តា?

មុត ៖ ទី២ ផនៗដូចតែខ្ញុំ ផនមានរស់ តែអ្នកទី២ និងទី៣ ។

ដានី ៖ ពូផន គាត់នៅណាឥឡូវ?

មុត ៖ ផន ដល់ពេលខ្មែរក្រហមបែកបាក់ វៀតណាមចូល គេរត់ទៅព្រៃ គាត់ខ្មែរ ក្រហមត្រូវមីន ផាប់នៅភ្នំឆ័ត្រ ។ អ្នកស្រុករហាលខាងកើតជប់នេះផង ។ ខ្ទើត ផង ខ្ទើតនៅភាស ។

ដានី ៖ ឈ្មោះអីគេ?

មុត ៖ ខ្ទើតអានោះកូនកងខ្ញុំដែរ គាត់កាន់កងអនុសេនាតូច ខ្ទើតបានប្រពន្ធនៅភាស ខ្ញុំប្រាប់លោក ហ៊ុយអស់ហើយ ។

ដានី ៖ ចឹងពូកាលនឹងបន្ទាប់ពីគេចាប់តាវ៉ាល់ទៅ ខាងកងបុរសមានតែតាវិតមួយទេ ដែលរត់ក្រុម តាវ៉ាល់ទេ?

មុត ៖ បាទ! តាវិតរត់ ។

ដានី ៖ កងទី២ ហើយកងទី៣ អត់ទេ?

មុត ៖ អត់ ។

ដានី ៖ ចុះខាងកងនារី គេអត់រត់?

មុត ៖ អត់មានណារត់ទេ រត់តែកងតាវិតមួយ ចាប់ផ្តើមរត់ ចាំមើលរត់ពីត្រឹមតាវិត ប្រធាន, អនុ ប្រធាន, កងអនុសេនាតូចៗមាន៣កងនោះទៅទាំងអស់ ។ នែក!តាវិតប្រធាន ហើយប្អូនតាវិន នោះក៏ទៅដែរ តាស្រេះ ឈ្មោះស្រេះ ។

ដានី ៖ បាទ! តាស្រេះ ទៅដែរ?

មុត ៖ បាទ! ទៅដែរ ។ ពួកនោះខ្លាចខ្លួននឹងខ្លួនឯងទៀត ។

ដានី ៖ បាទ! ប៉ុន្តែចឹងគេចាប់នឹង គេអត់មានមកប្រជុំ អត់មានមកណែនាំដួបពូទេ ខាងនិរតីមក?

មុត ៖ គេអត់មានប្រជុំប្រាប់ថា អ្នកនេះរត់ អ្នកនោះរត់អីទេ ។

ដានី ៖ គេអត់មានប្រជុំចាប់អ្នកនេះ ចាប់អ្នកនោះ កសាងអ្នកនេះ កសាងអ្នកនោះ គេមានមកប្រជុំ ប្រាប់ទេ?

មុត ៖ បាទ! អត់មានមកប្រជុំប្រាប់ទេ បាត់ជ្រាប ។

ដានី ៖ តាញ៉ែវក៏អត់មានមកនិយាយដែរ?

មុត ៖ តាញ៉ែវ គាត់អត់មានព្រុប្រជុំរឿងអ្នកណារត់ អ្នកណាអីទេ អត់ទេ ។

ដានី ៖ គាត់អត់មាននិយាយពីឈ្មោះតាវ៉ាល់ទេ?

មុត ៖ អត់ទេ ។

ដានី ៖ តាញ៉ែវ?

មុត ៖ អត់មាននិយាយពីឈ្មោះតាវ៉ាល់ ថាយ៉ាងណាយ៉ាងណៃ ។

ដានី ៖ អត់មាននិយាយពីឈ្មោះតាវ៉ាល់?

មុត ៖ មកហើយរិះគន់មកកាន់ឃើញមនុស្សនៅចង្រៃលមក អត់ឃើញពន្យល់ហេតុថា អូ!អត់ពីលោកនេះ លោកនោះទៅចេះចុះ អត់មានបង្ហាញហេតុផលអីទេ ។

ដានី ៖ អត់ទេនោះ?

មុត ៖ អត់ ស្វាត់ជ្រាប ។

ដានី ៖ តែពេលនឹងមានពួកនិរតីអីមក?

មុត ៖ អត់មានពិគ្រោះជាដូវការថា ឥឡូវខ្ញុំកាន់ជួសលោកនេះលោកនោះ លោកនេះទៅនេះទៅនោះ អត់ ស្វាត់ជ្រាប ។

ដានី ៖ ចុះពួកនិរតី មានមកចូលអី?

មុត ៖ និរតីមកចូលកន្លែងខ្ញុំ ចាប់ពីនិរតីចូលមក ខ្ញុំនៅតិចតួច ហើយបែកខ្មែកទៅ ខ្ញុំក៏គេដកមកកន្លែងមន្ទីរពេទ្យ ។ ចាប់ពីនិរតីមក គេដកមកកាន់កន្លែងពេទ្យទេ ពីអន្ទង់សារ ព្រីងដូយើងខាង បៀតព្រៃមាន់នោះ ។

ដានី ៖ ចឹងកាលនឹងពេលនឹង យើងផ្ញើរួចអស់នៅ ខាងទំនប់ត្រពាំងថ្ម?

មុត ៖ រួចអស់ហើយ បាទ! ។

ដានី ៖ រួចអស់ពីអន្តាល់?

មុត ៖ ចប់អស់ហើយ ។

ដានី ៖ ចប់ពីអន្តាល់?

មុត ៖ ក៏ប៉ុន្តែ ដែលចប់ទំនប់នោះលោកគ្រូ?

ដានី ៖ បាទ! ទំនប់ត្រពាំងថ្ម ។

មុត ៖ ដែលចប់រួចហើយនៅក្នុងឆ្នាំ៧៧ដដែល ដែលរួចអស់ហើយ ។ បាទ! ដែល នៅថែមថយអ្នកនៅប្រចាំការណ៍នោះ នៅតែថែមថយ ។

ដានី ៖ នៅចុងឆ្នាំ៧៧នឹង?

មុត ៖ បាទ!

ដានី ៖ ពេលគេចាប់ មុនចាប់តាវ៉ាល់តិច?

មុត ៖ បាទៗ ចាប់តាវ៉ាល់បែកបាក់រួច ក៏ខ្ញុំនៅមិនយូរប៉ុន្មានទេ វាបែកបាក់ក្រោយ តាវ៉ាល់ព្រោងប្រៀបដែរ ។

ដានី ៖ ចុងឆ្នាំ៧៧ ពេលតាញ៉ាវ គាត់មកធ្វើ៤ខែនឹង ធ្វើមកនឹងទំនប់ហើយនៅពេលតាញ៉ាវមក៤ខែ?

មុត ៖ បាទ! តាញ៉ាវមកហើយ ក៏ប៉ុន្តែដូចថាយើងនៅថែមថយដូចអាខ្វះដីវាសឹក រិច ។

ដានី ៖ ដូចជាស្ពានទី១ ទី២ តាញ៉ាវមកស្ពានទី៣?

មុត ៖ បាទៗ នៅថែមរហូត អាត្រង់ណាវាទាប ត្រង់ណាដែលរៀងទេរ រៀងថ្នក់ខ្វាំងទៅក៏តាញ៉ាវស្រាប់ថែមថយ ។ តាញ៉ាវមកថែមថយទេ អត់មានអីដុំកំភួន ទេ ។

ដានី ៖ បាទ! ដល់ពេលមកតាញ៉ាវមកបាន៤ខែ បាត់តាញ៉ាវទៀត?

មុត ៖ បាទៗ ។

ដានី ៖ បាត់តាញ៉ាវទៀត កាលនឹងពូនៅកន្លែងទំនប់ដដែល?

មុត ៖ នៅទំនប់ដដែល ក៏ប៉ុន្តែដល់ក្រោយមកទៀត ពួកនោះដូចជាឯកកោរធម្មតាណា ទៅណាដឹងវាព្រោងប្រៀបហើយលោកគ្រូ ចាប់បែកខ្ញែកទៅដូចកម្ទាំង នោះ អាទំនប់នោះក៏រួចហើយ ។ ក៏វាព្រោងប្រៀបទៅ ដូចគ្មានអ្នកណាទៅចង ក្រងថានៅទៀតនោះ ចាប់ផ្តើមរកច្រករៀងខ្លួនភ័យភិតរៀងខ្លួនស្ទុះរកច្រករៀងខ្លួនពេលនោះ ។ ដល់បែកខ្ញែក ក៏មិនមានអ្នកណាបញ្ជាថាទៅត្រង់ណាទៅត្រង់ណែ យើងត្រូវទៅត្រង់នេះ ត្រង់នោះវិញ អត់មាន ។

ដានី ៖ ដល់ពេលចប់ទំនប់ចប់ទៅយ៉ាងម៉េចពូ?

មុត ៖ រឿងនេះ រកចប់រកត្រូវថាឲ្យចប់ដើរទៅណា ឥឡូវពួកយើងចប់អស់ទៅត្រង់ នេះត្រង់នោះក៏ដូចជាវាមិនមានអ្នកណាប្រាប់ផង ស្រាប់តែវាបាត់រំដោះខ្លួន រួចតែខ្លួន ។

ដានី ៖ បាទ! ដល់ពេលចុង៧៧ ពូថាចប់នៅចុងឆ្នាំ៧៧នឹងដែរ?

មុត ៖ បាទ!

ដានី ៖ ហើយចុះពូដល់ពេលចប់ទៅ មិញពូមានប្រសាសន៍ថាមកពេទ្យ?

មុត ៖ បាទ!

ដានី ៖ អានឹងពូមកខ្លួនឯង?

មុត ៖ ទេ! មកខ្លួនឯងនោះ នែក!បងយឿកៗនេះអ្នកចាត់តាំងឲ្យមកកន្លែងអន្លង់ សារមក មកគ្នាប្រុស៣ ស្រី៣ ឲ្យមកកន្លែងមន្ទីរពេទ្យអន្លង់សារ ។

ដានី ៖ អានឹងមកធ្វើអី មកកន្លែងមន្ទីរពេទ្យនឹង?

មុត ៖ មកកន្លែងពេទ្យនោះ គាត់ឲ្យខ្ញុំមកនៅមើលពួកអ្នកជម្ងឺដែលនៅកន្លែង គេដាក់ទីតាំងពេទ្យមួយនោះនៅអន្លង់សារ ។

ដានី ៖ នៅណា?

មុត ៖ ពេទ្យអន្លង់សារ ព្រីងជូរ យើងត្រង់នេះ ។

ដានី ៖ អន្លង់ចារ ព្រីងជូរ?

មុត ៖ បាទ!

ដានី ៖ កាលនោះមិនមែនប្រធានគេចាត់តាំងអីទេ ចុះបងយឿក?

មុត ៖ បងយឿកៗបញ្ជូនខ្ញុំមក ។

ដានី ៖ បងយឿកនឹង គាត់ធ្វើអីទៅ?

មុត ៖ បងយឿកនោះ គាត់នៅជាមួយពួកតាវ៉ាល់ឯង ក៏ប៉ុន្តែគាត់នៅក្តាប់រួម ដូចពួកតាសន តែគាត់ផ្នែកខាងសេដ្ឋកិច្ច គាត់នៅខាងបើកអង្ករ ។ បងយឿកណា៎ សព្វថ្ងៃដែលនៅសាលាក្រហមនេះ គាត់ត្រូវជាបងធម៌លោក នួន ណារិទ្ធនេះ ឯង ។ បងធម៌ កាលគាត់មកនេះ គាត់ហៅបងយឿកនោះមកជួបដែរ ។ នួន ណារិទ្ធ នោះក្រោយមកទៀត ដកម៉ាកង់ខ្ញុំនេះឲ្យទៅនៅរែកខ្សាច់ឲ្យជាងធ្វើស្ពានដែរ ។

ដានី ៖ ធ្វើស្ពាននៅណា?

មុត ៖ ធ្វើស្ពានត្រពាំងថ្ម ។ ខ្ញុំនាំពួកនួន ណារិទ្ធ ទៅនៅយាងវ៉ាន ទៅបាខ្សាច់ពីបាតស្ទឹង រែកឡើងពីបាតស្ទឹងឡើងមកលើ ។

ដានី ៖ ចឹងលោកពូពេលដែល យើងដកមកកន្លែងមន្ទីរពេទ្យនៅអន្លង់សារ ព្រីងជូរ នឹងកាលហ្នឹងយើងមកតែ២-៣នាក់ទេ?

មុត ៖ ខ្ញុំមក៣នាក់ ប៉ុន្តែកម្លាំងដែលគេដេកពេទ្យដេកស្អីនៅនេះមកស្រេច គេមានស្រេច ។

ដានី ៖ មក ពូមកធ្វើប្រធានគេ?

មុត ៖ បាទ! គេមានស្រេច គ្រាន់ដូចខ្ញុំមកនៅមើលខុសត្រូវពួកអ្នកជម្ងឺនេះទៀត ។

ដានី ៖ មកធ្វើ មកមើលខុសត្រូវអ្នកជម្ងឺនៅពេទ្យអន្លង់សារនឹង?

មុត ៖ បាទ! មកនៅរឿងបាយ រឿងទឹកអីពួកខ្ញុំ ដូចថាស្តេស្តុរដែលគាត់ទៅពីណាពី ណៃ ខ្ញុំនៅទទួលខុសត្រូវទាំង៣នាក់ ។ ពួកនារីដែត, ខា, ខ្ញុំ, អាវុន, ហើយ ខ្មើត, ខ្ញុំ នេះ៣នាក់នេះឯងចាន់ៗស្លាប់ហើយ ចាន់ក្អំលាភ ។ ប្រុសមាន៣ ខ្ញុំ ។

ដានី ៖ ពេទ្យនៅអន្លង់សារនឹងពេទ្យរបស់អីគេ ពេទ្យរបស់?

មុត ៖ ពេទ្យកងចល័ត ដែលឈឺយកមកពីកងចល័ត ។

ដានី ៖ ពេទ្យនឹង ពេទ្យរបស់តំបន់ដែរ?

មុត ៖ ពេទ្យរបស់តំបន់ ។

ដានី ៖ ពេទ្យនឹង ពេទ្យរបស់តំបន់ដែរ?

មុត ៖ ពេទ្យរបស់តំបន់ បាទ! ។

ដានី ៖ ពេទ្យរបស់តំបន់៥នឹង ពេទ្យកងចល័ត?

មុត ៖ ពេទ្យកងចល័តតាវ៉ាល់ ។ អ្នកណាដែលឈឺច្រើន គេបញ្ជូនមកកន្លែងនេះឯង គេហៅពេទ្យអន្ទង់សារ ។

ដានី ៖ ពេទ្យអន្ទង់សារ?

មុត ៖ នៅមាត់ស្ទឹង អន្ទង់សារ ។

ដានី ៖ តែពូមកធ្វើ អឺ!ចុះកាលពីមុនពូមានអ្នកទទួលខុសត្រូវគេផ្សេង?

មុត ៖ មិនដឹងមានត្រង់ណាលោកគ្រូ ស្រាប់តែឃើញទៅក៏ឃើញខ្ញុំដូចថាផ្លាស់ឲ្យ ជួបតទល់ថាអ្នកណាមួយផ្លាស់ប្ដូរថាឥឡូវខ្ញុំគេឲ្យដកទៅត្រង់នេះវាមិនមាន ។
ហើយខ្ញុំទៅឃើញគេឲ្យកាន់កាប់នៅនេះ បណ្ដោយទៅ ។

ដានី ៖ កាលនោះចូលកាន់កាប់នោះមានគ្នា៣នាក់ មានពូ ឈ្មោះ?

មុត ៖ បាទ! ស្រី៣ ប្រុស៣ ។

ដានី ៖ ឈ្មោះ វុន ឈ្មោះ?

មុត ៖ ដែលកាន់កាប់នោះ វុន១, ចាន់១, ខ្ញុំ១ មុតនេះឯង១ ។ ហើយផ្នែកខាង នារីមានដែត១, សុខា១ ដែលនៅទំលាប់, ដែតនៅជើងវត្តព្រះនេត្រព្រះ, បាទ! ស្រី១ទៀតពីណាទេ ចែវិន្ទចាំមើលខ្ញុំសួរដែតច្បាស់ មិនដឹងចែអីមួយ ទៀតទេ ។

ដានី ៖ ចឹងកាលនឹងអ្នកដេកពេទ្យនឹងច្រើន?

មុត ៖ ច្រើន លោកគ្រូ ។

ដានី ៖ រាប់ប្រហែលប៉ុន្មាន?

មុត ៖ ដេកពេទ្យនឹង ប្រហែលជា៥០-៦០នាក់ ដេកតាមព្រៃ មានរោងស្បូវគេ ប្រក់ស្បូវធម្មតា ។

ដានី ៖ ស្បូវ ចុះកាលនឹងពូអត់ដែលធ្លាប់ធ្វើពេទ្យផង ពូទៅកាន់ពេទ្យ?

មុត ៖ ពេទ្យនឹងពេទ្យ មិនដឹងពេទ្យគេមកពីខាងណាទេ ខ្ញុំកាន់ដូចផ្នែកគេ ពេទ្យគេ ផ្សេង ។

ដានី ៖ យើងគ្រាន់តែធ្វើប្រធាន?

មុត ៖ ដូចខ្ញុំគ្រាន់តែនៅទៅជាអង្គរ ដូចជាស្អុរ សម្ភារៈសម្រាប់អ្នកជម្ងឺ ដឹងផ្នែកអីគេ គេកាន់នោះនៅកន្លែងត្រីផ្សៀត ត្រីអីនោះ ក៏ពួកខ្ញុំកាន់ក្តោបក្តាប់ទៅណា ពេទ្យគេដឹងថាពេទ្យៗមកពីតំបន់នេះឯងពេទ្យ ។

ដានី ៖ ពេទ្យគេមកព្យាបាលជម្ងឺ?

មុត ៖ បានមានអាពេទ្យ គេប្រគល់ឲ្យពេទ្យនឹង មិនដឹងថាធ្វើអីទេ ខ្ញុំដូចជាមិនយល់ដែរ បើនិយាយតាមផ្នែកសព្វថ្ងៃ ។

ដានី ៖ ចុះកាលនឹងពូទៅគ្រប់គ្រងនៅនឹង ពួកនិរតីអត់មានបានចូលទៅជាមួយ?

មុត ៖ បាទ! អត់ទាន់បានចូលទៅដល់ អត់មានទេ ពេលនោះបែកបាក់ហើយលោកគ្រូ មន្ទីរពេទ្យនោះ បែកបាក់ទៅ ។ ខ្ញុំកាលនោះវាឆ្ងាយៗខ្លួន ឆ្ងាយៗមកក៏ខ្ញុំ មកផ្ទះមក ។

ដានី ៖ ចឹងពូកាលនោះ ពូទៅទទួលខុសត្រូវនៅពេទ្យនឹងបានរយៈពេលប៉ុន្មាន?

មុត ៖ បាទ! ទៅទទួលនៅកន្លែងនោះ ប្រហែល៣-៤ខែដែរ ។

ដានី ៖ ៣-៤ខែ ហើយម៉េចទៀតទៅ?

មុត ៖ ពេលនោះខ្ញុំក៏ដល់ផ្តល់កម្លាំងធម្មតា ខ្ញុំក៏បែរមកកំបោរ គេបញ្ជូនមកកំបោរចេញពីនោះ ខ្ញុំមកនៅកំបោរ ស្រែះ នៅភ្នំកំបោរនេះ ចេញពីពេទ្យមកខ្ញុំមក នៅកំបោរ ។

ដានី ៖ មកធ្វើអីនៅភ្នំកំបោរ?

មុត ៖ បាទ! មកនៅភ្នំកំបោរកាលនោះ គេបញ្ជូនមកច្រូតស្រូវ អស់រឿងទំនប់ហើយ ច្រូតស្រូវម្តងៗ ចូលដូចកម្លាំងណាណែទេ លោកគ្រូខ្ញុំ ។

ដានី ៖ គ្នាប៉ុន្មាននាក់មកនៅនឹង?

មុត ៖ បាទ! ដែលខ្ញុំមកនៅនោះ មកគ្នា មកច្រើនដែរលោកគ្រូ ខ្ញុំមកប្រហែលម៉ាកងប្រហែលជា ៣០-៤០នាក់ដែរ ។ ហើយមានកម្លាំងគេចាស់នៅនេះផង ដូចថាមករួមជាមួយគេ ។

ដានី ៖ ពីណាបញ្ជូនមក?

មុត ៖ បាទ?

ដានី ៖ ពីណាបញ្ជូនមក?

មុត ៖ ខ្ញុំកាលដែលមក បងយៀកនេះឯង អ្នកឲ្យខ្ញុំមកនៅច្រូតស្រូវ ថាទៅភ្នំកំបោរ ផ្លាស់ពីនោះមកដកតាមខ្ញុំមកតាំងពីនេះអន្លង់សារ លោកគ្រូ ។

ដានី ៖ អន្លង់សារ?

មុត ៖ បាទ! នៅច្រូត ។

ដានី ៖ ច្រូតរយៈពេលប៉ុន្មានទៅ?

មុត ៖ បាទ! ច្រូតមិនយូរទេ ច្រូតប្រហែលជាម៉ាខែ ដេកតាមទំនប់ តាមអីនឹងឯង ។

ដានី ៖ បានម៉ាខែហើយម៉េចទៀតទៅ?

មុត ៖ បានហើយលោកគ្រូបណ្ដោយ វាដេកបណ្ដោយក៏ខ្ញុំក៏ចប់អាច្រូតនោះក៏ឡើង មកៗតាមធម្មតា ឡើងមកជប់នេះ បាទ!ៗ រកប្រាប់អាត្រង់នេះ ដូចយើង រកថាមិនត្រូវប៉ុនមានអ្នកណាតាមចងក្រងតាមក្ដោបក្ដាប់ឲ្យជាប់ក៏បែកខ្ញែកពីនោះមកឲ្យល្អល្អិត ។ វាទៅដូចថា ពេលណាឲ្យព្រោងប្រៀបក៏ ដូចថាយើងបែកបាក់គ្នា ក៏បែកបាក់ដោយចៃដន្យ ទល់គេមានរឿងរ៉ាវបែកគ្នាក៏បែកទៅ ។

ដានី ៖ យើងដូចអស់តួនាទី អស់មេកើយអី?

មុត ៖ បាទ! រកប្រាប់លោកគ្រូឯង រកប្រាប់មិនត្រូវទេ ត្រង់នេះ ដូចរៀងត្រដោះ ខ្លួនរៀងខ្លួន ។

ដានី ៖ ដល់ពេលពូមកដល់ជប់វ៉ារីហើយ ម៉េចទៀតទៅ?

មុត ៖ មកជប់វ៉ារី ក៏ខ្ញុំមកផ្ទះម៉ាភ្លែត មកផ្ទះក៏ខ្ញុំដើរៗ ម្ដងនេះឆ្នាំរៀតណាមចូលមកទៀត ។ ចប់ក៏ព្រួតព័ត៌មានព្រួអីក៏នាំគ្នា ទេ!និយាយចេះនិយាយចេះតែឃើញ ដល់វៀតណាមចូលព្រួសម្ដេងតាម រ៉ាដ្យូលោកគ្រូ ស្ដាប់បានចេះដោះៗខ្លួន រៀងខ្លួន ។ ខ្ញុំដោះបងប្អូនណាទៅក៏ទៅ ។

ដានី ៖ ចឹងពេលលោកពូ ពេលដែលលោកពូមកជប់វ៉ារីនឹង វៀតណាមចូល?

មុត ៖ ទេ! ដែលខ្ញុំឡើងមក ។

ដានី ៖ ជប់វ៉ារី?

មុត ៖ មិនទាន់ទេលោកគ្រូ មិនទាន់ទេ ។ មកបានយូរគ្រាន់ បាន ។

ដានី ៖ មកធ្វើអីនៅជប់វ៉ារី?

មុត ៖ ដែលខ្ញុំឡើងពីនោះមក ខ្ញុំឡើងមកជប់វ៉ារី មករកគ្នីគ្នាខ្ញុំដែលនៅចាំមើលគេទៅ ណាទៅណែ ។ ទៅក៏គេបែកខ្ញែកគ្នាឯង ក៏មិនឃើញ បែកខ្ញែកគ្នាម៉េចទៅណា គេទៅផ្ទះមកនៅតាមសហករណ៍ម៉ែឪនៅតាមសហករណ៍នោះណា ។ ចេញមកខ្ញុំក៏ ខ្ញុំមកដែរ ដល់មកដែរមកនៅផ្ទះបានយូរគ្រាន់ដែរ ។

ដានី ៖ មកនៅផ្ទះតាមសហករណ៍នឹង?

មុត ៖ បាទ! ខ្ញុំ ទេ!គេផុតពីសហករណ៍ហើយ ។

ដានី ៖ នៅផ្ទះធ្វើអីវិញ?

មុត ៖ ខ្ញុំមកអាក្រោយ ដែលគេចប់ៗហើយបានខ្ញុំមកផ្ទះ ។

ដានី ៖ អូ! ពេលយួនចូលហើយ បានមកផ្ទះ?

មុត ៖ ទៅនៅយួនចូលបានខ្ញុំមក លោកគ្រូ ។

ដានី ៖ អូ!ចឹងកាលពូទៅនៅជប់ភារី បានរយៈពេលប៉ុន្មានទៅ?

មុត ៖ ដែលខ្ញុំឡើងមកជប់ភារីនឹងប្រហែលជា២-៣ខែ ដែលខ្ញុំឡើងពីកំពោរ ។

ដានី ៖ នៅធ្វើអីទៅនៅជប់ភារី?

មុត ៖ នៅជប់ភារី ខ្ញុំនៅកន្លែងការដ្ឋាននោះឯង ។

ដានី ៖ ការដ្ឋានធ្វើអី?

មុត ៖ ការដ្ឋានកាលនោះនៅជាមួយពួកកងក្រុមដាល តានេះគេចាប់ហើយ តាឆាង ដែលខ្ញុំនៅចាស់ៗ កាលនោះខ្ញុំបានបែកចេញនោះលោកគ្រូ ដែលខ្ញុំឡើងពី ទំនប់ ខ្ញុំឡើងទៅរកកន្លែងនោះឯង គេចាប់នោះ តែគ្មានគោលដៅខ្ញុំៗនៅ ធម្មតា ។

ដានី ៖ ការដ្ឋានគេធ្វើអីការដ្ឋាននឹង?

មុត ៖ ការដ្ឋានមានអីដើរស្ទូងស្រូវ ជួយស្ទូងស្រូវអ្នកស្រុក ចុះគៀនៗត្រង់នោះឯង ការដ្ឋានគេ ព្រឹកឡើងទៅស្ទូងទៅដកសំណាបអីដែរ ។ ចឹងការងារនេះឡូឡាយ កំប៉េចកំប៉ុកលោកគ្រូ ។

ដានី ៖ ពីណាគេធ្វើប្រធាននៅនឹង?

មុត ៖ សាងសង់ ការដ្ឋានតាឆាងនោះឯងប្រធាន ។

ដានី ៖ ប៉ុន្តែតាឆាង ក្រែងគេចាប់?

មុត ៖ អូ! ប្រធានការដ្ឋាន បងយឿក ។

ដានី ៖ អូ! យឿក ចាំនេះ?

មុត ៖ បងយឿកនឹងឯង អ្នកក្តាប់ក្រុមយុទ្ធជនការដ្ឋាន បាទ!ក្រុមគេៗដកទាំងបង យឿក ទាំងខ្ញុំនេះ ឯងទៅនោះដែរ ។

ដានី ៖ ទៅណា?

មុត ៖ ទៅឯត្រពាំងថ្ម កាលនោះណាៗ ទេ! កាលដែលគាត់ដកៗទាំងបងយឿក ទាំងអីទាំងប្រធាន ទាំងអីណាៗ ។

ដានី ៖ បាទ! ចាំមើលពូមានប្រសាសន៍មិញថា ពេលដកពីត្រពាំងថ្មទៅ អន្លង់សារ ទៅក្តាប់ពេទ្យ?

មុត ៖ បាទ!

ដានី ៖ ដល់ពេទ្យហើយ បានពូមកច្រូតស្រូវនៅភ្នំកំពោរ?

មុត ៖ ភ្នំកំបោរ ។

ដានី ៖ បាទ! ចេញពីភ្នំកំបោរឡើងមកជប់រ៉ាវី?

មុត ៖ បាទៗ ។

ដានី ៖ ដល់ជប់រ៉ាវី នៅកន្លែងការដ្ឋាន?

មុត ៖ នៅកន្លែងការដ្ឋាន ។

ដានី ៖ ជួយច្រូតស្រូវជាមួយ?

មុត ៖ មកកន្លែងចាស់ កន្លែងការដ្ឋាន ដែលគេដកខ្ញុំទៅចល័ត ខ្ញុំនឹងមករកកន្លែងការដ្ឋានចាស់ខ្ញុំវិញ ។

ដានី ៖ កន្លែងចាស់?

មុត ៖ បាទ!

ដានី ៖ ប៉ុន្តែឈ្មោះ បងយៀក នឹងគាត់ធ្វើប្រធានគ្រប់គ្រងនៅនឹង?

មុត ៖ បងយៀក គ្រប់គ្រងនោះ បងយៀកគាត់គ្រប់គ្រងចាស់ កន្លែងការដ្ឋានចាស់ ដែលមុនគេដកទៅតាវ៉ាល់ ។ គាត់ដកទៅលេងការដ្ឋាននឹងដែរ ទៅជាមួយខ្ញុំដែរ ដែលដកទៅណា ។ ដកទៅកាន់ចល័តតាវ៉ាល់ តាយៀកទៅដែរ កាលដែលនៅការដ្ឋាន តាយៀកកាន់នៅនឹងដែរ ។ ពេលនេះ ។

ដានី ៖ ជាមួយតាឆាងនឹង?

មុត ៖ បាទ! ជាមួយតាឆាង ដល់មកខ្ញុំទៅរកអាកន្លែងនេះទៀត ។

ដានី ៖ តាយៀក គាត់មកជាមួយគ្នា ជាមួយពូដែរ ហើយក៏គាត់មកនៅកន្លែងជប់រ៉ាវី មុនពូ?

មុត ៖ បាទ! បងយៀក អត់ឃើញទេ កាលដែលបែកបាក់ គាត់នៅគោកគី គាត់ នៅផ្ទាស់ប្តូរជាមួយតាពាល់ នៅធ្វើស្រែប្រាំងយើង ខាងផ្លូវតីយើងគោកគី ដូចភ្នំលាភនោះបង ។ ដល់ពេលនេះ គាត់និងខ្ញុំ ត្រូវបែកមុខសញ្ញាគ្នា បងយៀក និងខ្ញុំ បែកគ្នាម៉ារយៈពេលតូច ។ ខ្ញុំថាពេលៗដែលបងយៀក នៅធ្វើស្រែ បងយៀកមិនទាន់ដកពីកន្លែងការដ្ឋានគោកគីផង យួនចូលមកដល់ក្រឡាញ់ហើយ ។ បាទ! យួនចូលមកដល់ក្រឡាញ់ៗ តាយៀកផ្ញើលផុស ទាក់ទងខ្ញុំ២នាក់ ចង់នាំគ្នារត់ទៅផ្លូវស្ពានស្រែង រត់ចូលព្រៃនាំគ្នាផ្អើលហើយ ណាលោកគ្រូ ចាប់ផ្ដើមផ្អើល ។

ដានី ៖ បាទ! ចឹងពេលពូទៅកន្លែងការដ្ឋាន ចេញទៅកន្លែងការដ្ឋាន នៅជប់រ៉ាវីនឹង បានតែ៣ខែទេ?

មុត ៖ ការដ្ឋាននោះ វាមិនដល់ប៉ុននោះផង តាមដែលខ្ញុំស្មាននោះលោកគ្រូ ។

ដានី ៖ បាទ! ប្រហែលជា៣ខែ?

មុត ៖ ក៏ប៉ុន្តែខ្ញុំ នៅនោះនៅសាំឡាន់ដូចថាមិនមានការផ្សារជាប់លាប់ដូចពីដើមទេ វា ចូលថាប្រជាពលរដ្ឋទៅស្ទូងទៅដកនឹងគេ លោកគ្រូ ។ ការដ្ឋាននេះ បង់បាត់ បង់ តែកម្លាំងនៅការដ្ឋានតាផាង១ ធម្មតា ខ្ញុំចង់ទៅចូលកម្លាំងចាស់នឹងឯង ដូចថាធ្លាប់ស្គាល់គ្នាចូលកន្លែងនោះទៅ ដូចថាវាសាំឡាន់ អាកម្លាំងធំវាបែកគ្នា បងប្អូនដែលជម្លៀស ក៏ខ្ញុំមុខសញ្ញាកងចល័តនោះ គ្នាបែក១ លាទៅស្រុកទៅ ស្រែទៅនៅតាមសហករណ៍គេណា លោកគ្រូ ។

ដានី ៖ បាទ១ ។

មុត ៖ បាទ! ទៅរកបងប្អូន ។

ដានី ៖ ហើយចឹងចេញពីកន្លែងការដ្ឋាននឹង ទៅណាទៀត?

មុត ៖ បាទ?

ដានី ៖ ចេញពីការដ្ឋានដែលពូនឹង?

មុត ៖ ចេញពីកន្លែងការដ្ឋាននេះ បងយឿកនេះ ត្រូវហៅខ្ញុំទៅគោកកី ទៅកន្លែងការដ្ឋាន អាកន្លែងគាត់នៅធ្វើស្រែនៅគោកកី ដូនទេវ ។

ដានី ៖ គោកកីធ្វើស្រែ?

មុត ៖ បាទ! ធ្វើស្រែ ។ ពេលនោះនិរតីក្តាប់ ដែលធ្វើស្រែនិរតីក្តាប់ទាំងបងយឿក និងខ្ញុំ ។

ដានី ៖ និរតីឈ្មោះអី?

មុត ៖ មេដែលក្តាប់នោះឈ្មោះ តាពាល់១ តាហួត ។

ដានី ៖ តាពាល់ តាហួត?

មុត ៖ សុទ្ធតែនិរតីទាំង២នាក់ ។

ដានី ៖ អ្នកនិរតី?

មុត ៖ បាទ!

ដានី ៖ នៅនឹងបានយូរទេ?

មុត ៖ នៅនោះយូរណាស់លោកគ្រូអើយ រាប់ឆ្នាំ ។

ដានី ៖ នៅណា?

មុត ៖ បាទ! នៅនឹងគោកកី ។

ដានី ៖ នៅគោកកីបានប៉ុន្មាន?

មុត ៖ នៅនឹងគោកកីឡើងយូរ ឡើងច្រូត បានម៉ារដូវច្រូតហើយ ។

ដានី ៖ បានម៉ារដូវ?

មុត ៖ បានម៉ារដូវប្រូតរួចបាន កាលនោះកន្លែងសន្តិសុខ កន្លែងគុកនៅវែថ្ម នៅភ្នំតាយោង យាយ ថែម កាលនោះគាត់មិនទាន់ចេញពីភ្នំលាភដែរ ។ កាលនោះដល់ យួនចូលមកដល់តាប៉ុន វថក្រោះមកភ្លើងអញ្ច្រាចមកដល់ស្ពានតាប៉ុននឹង ក្រឡាញ់នេះហើយ តំរង់ឆ្ពោះមកភ្នំលាភ លោកគ្រូ ។ ដល់ភ្នំលាភ យាយថែម រត់ផ្អើល ខ្ញុំក៏បានជួបនឹងបងយឿកនៅពេលនោះម្តង ទៀត ។ ស្រេចនឹងយើង រត់ បងយឿករត់ទៅព្រៃ ខ្ញុំរត់មកផ្ទះ ។

ដានី ៖ ចឹងពេលដែលពូធ្វើការដ្ឋាន ធ្វើប្រូតស្រូវបានម៉ារដូវហើយ?

មុត ៖ បាទ!

ដានី ៖ បានម៉ារដូវហើយ បានយួនចូល ហើយក៏យ៉ាងម៉េច?

មុត ៖ បានម៉ារដូវរួចហើយ បានយួនចូល ។

ដានី ៖ បានម៉ារដូវហើយបានយួនចូល?

មុត ៖ បាទៗ ។

ដានី ៖ បានយួនចូល ពូរត់មកផ្ទះមក?

មុត ៖ យួនចូល បងយឿកនេះហើយនាំខ្ញុំទៅព្រៃ ខ្ញុំមិនបានចូលទៅព្រៃទេ ។

ដានី ៖ បងយឿកអ្នកនាំពូទៅព្រៃ ប៉ុន្តែពូអត់បានចូលព្រៃ ពូរត់មកផ្ទះ?

មុត ៖ បាទ! ពីណាពីណៃ ពីបាត់ដំបង ពីភ្នំពេញអី គេនាំស្មុះទៅភ្នំដងរែក ទៅកាន់ភ្នំ ដងរែក ខ្ញុំអត់ទៅ ។ ទៅតែបងយឿក រហូតដល់អ៊ុនតាក់ចូល បានជួបបង យឿកម្តងទៀតខ្ញុំ ។

ដានី ៖ ចុះពូ កាលនឹង កាលយាយថែម គាត់មកធ្វើគណៈស្រុកព្រះនេត្រព្រះ?

មុត ៖ យាយថែមមកធ្វើគណៈស្រុកនឹងឆ្នាំលោកគ្រូ ប្រហែលជាឆ្នាំ ។

ដានី ៖ ពេលចាប់តាមោង មុននឹងចាប់តាមោង?

មុត ៖ ប្រហែលជាវ៉ាវៗ ខ្ញុំថាវ៉ាវៗឆ្នាំ៧៧ ដើម៧៦ ចុង៧៦ ៧០អីនេះហើយ ។

ដានី ៖ ចឹង?

មុត ៖ បាទ!

ដានី ៖ ចឹងមកយូរហើយ មកមុនធ្វើទំនប់ទៀត ជំនាន់ធ្វើទំនប់ ហើយក៏?

មុត ៖ ទេ! មិនដឹងទេដឹងលោកគ្រូ យាយថែមមកនេះ បែបជាមកក្នុងវ៉ាវៗ៧៨ ៧៧ ចុង៧៧ ដើមចង់ចូល៧៨ ។ ចេះ ព្រោះ៧៨ ៧៩យួនចូល ហ៊ា! និយាយ ។

ដានី ៖ គាត់មកជំនួសតាមោង?

មុត ៖ បាទ! គាត់ឡើង ។

ដានី ៖ កាលនឹងគាត់មក គាមោងគេចាប់នៅ?

មុត ៖ បាទ! គេចាប់រួចហើយ ។

ដានី ៖ គេចាប់ហើយ បានយាយថែមមក?

មុត ៖ បាទៗ យាយថែមមក ។

ដានី ៖ យាយថែមមក គាត់ធ្វើគណៈស្រុក?

មុត ៖ យាយថែមមកអត់បានយូរប៉ុន្មានទេលោកគ្រូ យាយមថែមមកអត់បានយូរ ប៉ុន្មានទេ ។

ដានី ៖ ចុះពូដែលបានជួបយាយថែមទេ?

មុត ៖ ជួប ។

ដានី ៖ ស្គាល់គាត់ដែរចឹង?

មុត ៖ ស្គាល់ ។

ដានី ៖ គាត់ស្គាល់ពូទេ?

មុត ៖ សព្វថ្ងៃអត់ស្គាល់ទេ បើសិនណាតែឃើញបានស្គាល់ តែខ្ញុំនៅតែស្គាល់គាត់ ។

ដានី ៖ កាលនឹងយាយថែម គាត់?

មុត ៖ យាយថែមកាលដែលយួនចូលមកដល់ គាត់កំពុងកើតកូនៗយប់នេះហើយ យួនចូលមកដល់គាប៉ុន ក្រឡាញ់ កើតកូនឈាមលលាក់ទៅៗទាំងនោះហើយ ។ ទៅចេញភូមិគោកកីបណ្តោយហើយ ឆ្ពោះទៅព្រៃដងស្ទឹងចេញទៅ ដើងនោះ ។ ទៅកើតកូនយប់នោះដែរ ។

ដានី ៖ យួនចូលមក គាត់ឆ្លងទន្លេ?

មុត ៖ បាទ! ឆ្លងទន្លេ ។

ដានី ៖ ហើយគាត់ទៅទាំងថ្ងៃឆ្លងទន្លេ?

មុត ៖ បាទ! ទៅទាំងឆ្លងទន្លេ កូនចេញពីពោះអស់រួចហើយ និរសាគាត់អី ។

ដានី ៖ ចុះយាយថែមកាលនឹងគាត់មក គាត់ត្រឹមគណៈស្រុកព្រះនេត្រព្រះ គាត់អត់មានតួនាទីគណៈតំបន់អីទេ?

មុត ៖ អត់ទេ មុខការគេ តែយើងដឹងមិនដល់ ទៅតាមមើលបែបគេ ។

ដានី ៖ កាលនឹងយាយថែម មានពីណាទៀត យាយថែមគាត់គណៈស្រុក ដល់ពេលមានពីណាបន្ទាប់គាត់ទៀត?

មុត ៖ អត់មានទេ ឃើញតែគាត់មក ប៉ុន្តែមានប្រុសៗនឹង មិនដឹងយ៉ាងណានឹងគាត់ ទៅ ។

ដានី ៖ តែមានពូឈ្មោះ រាមទេ?

មុត ៖ រាម ចៅហ្វាយស្រុកថ្មពួក ។

ដានី ៖ រាម ចៅហ្វាយស្រុកថ្មពួក?

មុត ៖ បាទ! រាម សារាមៗ រហូតដល់ទៅព្រៃទៀត ។ បើជួបបងយឿក បាន ការណ៍ច្រើនៗ បងយឿកដឹងច្បាស់ តាមជាប់ពួកនោះ ។

ដានី ៖ ប៉ុន្តែ ចាំមើល កាលជំនាន់តាមោងៗហើយនឹង តាសំអាត?

មុត ៖ តាសំអាត ម៉ាសេរីគ្នាគាត់ហើយនោះ ។

ដានី ៖ ហ្នឹងនៅគណៈស្រុកព្រះនេត្រព្រះ ដល់ពេលតាមោង ហើយតាសំអាតគេចាប់ ទៅ យាយចែមមក?

មុត ៖ យាយចែមមក ។

ដានី ៖ យាយចែមមកតែយាយចែមម្នាក់ឯង មានពីណាផ្សេង?

មុត ៖ បាទ! មាននឹងឯង ក្រុមយោធា ស្រីៗប្រុសក៏មាន បន្ទាប់ពីយាយចែម ប៉ុន្តែមិនដឹងថាផ្នែក អីក្មេងៗដែរ ។

ដានី ៖ ពូស្គាល់តែយាយចែមទេ?

មុត ៖ បាទ! ស្គាល់តែជើងដៃគាត់ ។

ដានី ៖ ចុះឈ្មោះ រាមៗ ពូស្គាល់គាត់ដែរ?

មុត ៖ រាម ពូបង ប៉ុនមិនដឹងថាការងារគាត់ បងសារាម ដែលនៅធ្វើចៅហ្វាយស្រុក ថ្មពួកស្គាល់ ។

ដានី ៖ ហ្នឹង ប្រពន្ធគាត់ឈ្មោះអីដែរ?

មុត ៖ អត់ស្គាល់ឈ្មោះទេ បង ។

ដានី ៖ រាម គាត់សំបុរម៉េច?

មុត ៖ រាមខ្មៅដែរ ខ្មៅស្រអែម មាឌរៀងធំតិចដែរ ។

ដានី ៖ ឥឡូវគាត់នៅដែរ?

មុត ៖ សព្វថ្ងៃនៅតើបង នៅព្រៃដែរ តាហួត ដែលនៅជាមួយតាពាល់ របស់តា ពាល់ស្លាប់ បើតាហួតដែលនៅជាមួយធ្វើស្រែប្រាំងនៅគោកកីនៅ ។ តែពូថា ធ្វើអធិការនៅបាត់ដំបង តាហួត គាត់ចៅហ្វាយរបស់ខ្ញុំដែរ គាត់និរតី តែ គាត់ស្រឡាញ់ខ្ញុំដែរ ប្រពន្ធគាត់ឈ្មោះយាយ សង ។

ដានី ៖ យាយ សង?

មុត ៖ បាទ! តាហួតនោះ ។

ដានី ៖ តាពាមនឹង ឥឡូវគាត់នៅណា?

មុត ៖ តាពាម សង្ស័យនៅភ្នំព្រឹក្សនឹងឯង ព្រោះគាត់នៅពួកផ្កាច់ខ្លួន គាត់នៅខាង នោះឯង ។

ដានី ៖ ចុះយាយថែមរៀងម៉េចគាត់ យាយថែម?

មុត ៖ យាយថែម ស្អាតណាស់ កាលពីខ្ញុំឃើញ សព្វថ្ងៃមិនដឹងយ៉ាងណា សព្វថ្ងៃ ចាស់ហើយ ។ កាលដែលខ្ញុំឃើញស្អាតដែរ អាយុប្រហែល៣០កន្លុយធំ៤០ ហើយ យាយថែម កាលដែលគាត់មក គាត់មិនក្មេងប៉ុន្មានដែរ ។ កាលដែល គាត់មកពាក់អាវខ្មៅបំពង់ដៃចេះផែក ចង្កេះ ស្លៀកសំពត់ខ្មៅ អាវខ្មៅ ដូច ចិន ។

ដានី ៖ ខ្មៅ ហើយស?

មុត ៖ ស ។សាច់ពងមាន ស្អាត យាយថែមស្អាតណាស់ សាច់ឡើងរលីងយ៉ង់ កាលខ្ញុំមកគាត់កាត់ សក់ការ៉េប្រវែង ។ នេះ ។ ខ្ញុំថាចិនតើ ស្មានតែចិនមកពី ស្រុកប៉េកាំង កាលគាត់មកស្អាត ណាស់ ។

ដានី ៖ ប្តីគាត់ឈ្មោះអី?

មុត ៖ ប្តីគាត់ឈ្មោះ តាញ៉ុនចេះអី ។

ដានី ៖ តាញ៉ុន?

មុត ៖ ញ៉ុន ឮតែតាញ៉ុន ខ្ញុំអត់ទាន់ច្បាស់ដែរ ។

ដានី ៖ ចឹងពូអត់ដែលបានធ្វើការជាមួយគាត់ដែរ?

មុត ៖ អត់ដែលបានធ្វើការជាមួយទេ ដោយឡែក ក៏មិនដែលដឹងថាគាត់ ដឹងថាគាត់ចៅហ្វាយស្រុក ព្រះនេត្រព្រះ គាត់មកនៅកាន់ការស្រុកព្រះនេត្រព្រះ ។

ដានី ៖ ផ្ទះគាត់នៅណា?

មុត ៖ ផ្ទះគាត់នៅភ្នំលាភ ។

ដានី ៖ ផ្ទះគាត់នៅភ្នំលាភ?

មុត ៖ សំណាក់នៅស្រុកព្រះនេត្រព្រះ ប៉ុន្តែគាត់ទៅដេកតែភ្នំលាភ ។

ដានី ៖ ម៉េចចឹង?

មុត ៖ មិនដឹងយ៉ាងណា អត់ដេកនៅកន្លែង ដេកផ្ទះតាមោងផង ។

ដានី ៖ អត់ដេកផ្ទះតាមោង?

មុត ៖ បាទ! ក៏ប៉ុន្តែស្រុកភ្នំលាភ វាមិនឆ្ងាយគ្នាពីព្រះនេត្រព្រះប៉ុន្មានដែរ វាជិតដែរ គាត់ចង់ទៅដេក នៅនឹង ។

ដានី ៖ គាត់ជិះអីកាលនឹង?

មុត ៖ ជិះម៉ូតូធម្មតា ។

ដានី ៖ គាត់ជិះម៉ូតូ អត់ជិះឡានហ្វីពស្អាត?

មុត ៖ អត់ទេ អត់មានឃើញឡានជិះអី ។

ដានី ៖ ជិះម៉ូតូៗអីម៉ាក់ម៉ូតូ?

មុត ៖ ម៉ូតូសេអិលខៀវ ។

ដានី ៖ សេអិលខៀវ?

មុត ៖ សេអិលខៀវ ក៏មិនមែនគាត់ជិះខ្លួនគាត់ មានគេឌុបគាត់ ។

ដានី ៖ គេឌុបគាត់?

មុត ៖ និរសាគាត់ បាទ! សេអិលខៀវពី សម័យលន់ នល់ ។

ដានី ៖ ពណ៌ខៀវ?

មុត ៖ ខៀវ រៀងជំនុំគ្រាន់ដែរ រៀងចាស់ ។

ដានី ៖ ចុះយាយថែមគាត់មកកាន់យ៉ាងម៉េចដែរ គាត់?

មុត ៖ យាយថែមមក អត់ទាន់មានជីវប្រវត្តិអីទេ បង ឃើញដើរមើលៗតាមទំនប់ តាមប្រឡាយ ព្រែកជីកអីធម្មតា ។ កាលនោះខ្ញុំនៅ២នាក់ គាសនៗដែលថា គេចាប់ពីអាងត្រពាំងថ្ម ដែល ក្តាប់ខ្ញុំនោះ ទៅធ្វើស្ពានស្រែង ព្រែកជីក ឃើញទៅមើល យាយថែមមកដល់ដើរមើលគ្រប់ កន្លែងរបស់តាវ៉ាល់កាន់កាបទាំងអស់ ។ ខ្ញុំមិនបានចងចាំអារឿងឆ្នាំប៉ុននេះ ប៉ុននោះ បើនៅ ក្មេចៗ អារឿងឆ្នាំនោះលោកគ្រូ រឿងឆ្នាំចេះចុះ ដូចថាវាឯកកោរដូចជាគ្មានតាម សណ្តាប់ទេ បើនិយាយយកកញ្ចប់ៗ វៀតណាមចូលយកឲ្យចប់ ។ តែវៀតណាមចូលមក ត្រឹមថាយាយ ថែមបែកៗត្រឹមវៀតណាមចូលមកដល់ក្រឡាញ់ យាយថែមចេញពីភ្នំលាភ ខ្ញុំចេញពីគោកកី ទៅព្រៃបាត់ ។

ដានី ៖ ចេញទៅនៅព្រៃរយៈពេលប៉ុន្មាន?

មុត ៖ បាទ?

ដានី ៖ ចេញទៅនៅព្រៃរយៈពេលប៉ុន្មាន?

មុត ៖ ខ្ញុំមកដល់ផ្ទះនេះបានតែរយៈពេល១ខែ-២ខែទេ ខ្ញុំត្រូវចេញទៅព្រៃទៀត ។

ដានី ៖ អូ! មកដល់ខេត្តហើយចេញទៅព្រៃវិញទៀត?

មុត ៖ ពុទ្ធពាក្យឃោសនាគេថា យួនចាប់ វះស្មៅ ស៊ីថ្ម ស៊ីគ្រោះ ខ្ញុំផ្អើល អារឿងអតីតនោះ រត់ទៅព្រៃនោះ ។ រត់ទៅព្រៃកើតប៉ាវ៉ា កាលនឹងនៅក្នុងចលនា ទៅ កើតប៉ាវ៉ាៗទៅព្រៃដុតធ្យូងយកទៅលក់ឲ្យថៃ អារដើម្បីបានប្រាក់ ដូចចោរព្រៃចឹង ។

ដានី ៖ ចឹងពូមកផ្ទះៗពី៧៩នឹង មកផ្ទះបាន២-៣ខែ?

មុត ៖ បាទ!

ដានី ៖ រត់ទៅព្រៃទៀត?

មុត ៖ រត់ទៅព្រៃម៉ាជាន់ទៀតៗ បានយូរអង្វែង ។

ដានី ៖ កាលនឹងទៅជួបយាយថែម ដែលអត់?

មុត ៖ អត់បានជួប ។

ដានី ៖ ដែលរត់ទៅ?

មុត ៖ ទេ! រត់ទៅបានជួប នៅដោយឡែកពីគ្នា អត់បាននៅជាមួយទេ ជួបៗ ក៏ប៉ុន្តែគាត់មានពួកថៃ ក្រហមពីលើចុះមកពីលើគាត់ ដែលពួកបងសារាមបងអីដែលបាក់បែកពីស្រុកទៅ មានគ្នាគេ ខ្មែរក្រហមដូចគ្នា ។

ដានី ៖ បងណា បងសារាមនឹង?

មុត ៖ បងសារាម ថ្នពួកនឹង ។

ដានី ៖ អូ! បងនេះ គណៈស្រុកថ្នពួកនឹង?

មុត ៖ មានពួកជនជាតិថៃ វាចង់ទទួលយកឡើងទៅលើភ្នំ ។

ដានី ៖ ចឹងកាលយាយថែម រាម ហើយគាត់មកកាន់នឹង កាន់នៅស្រុកនឹង ដូចថាកាលនឹងមានការចាប់ ការសម្លាប់អីច្រើនដែរអត់?

មុត ៖ កាលដែលពួកយាយថែមមកនឹង មានៗតើបង មានចាប់ខ្លះដែរ មានចាប់មិន ដែលឃើញវ៉ៃនឹងមុខចាប់ទៅរៀន សល់ឈ្មោះចោល ដោឈ្មោះទៅយកទៅណា ។ ចាប់កាលនោះ ពួកនៅកន្លែងគុកភ្នំតាយោងក៏បែកបាក់គ្នាត្រឹមដែល វៀតណាមចូលដែលរហែកគុករហែកអី បងខ្ញុំស្លាប់ក្នុងគុក ។

ដានី ៖ ចុះពូកាលជំនាន់តាវ៉ាល់ កាលជំនាន់តាហ៊ុង ប្រៀបធៀបកាលជំនាន់តាវ៉ាល់ កាលជំនាន់តាហ៊ុង ហើយនឹងជំនាន់ក្រោយយាយថែមអីនឹងមួយណា..... (ស្តាប់មិនបាន) ជំនាន់ពួកនិរតីមក ក្រោយនឹង?

មុត ៈ មកខុសទេ ដូចតែគ្នាទេ ឃើញតែចាប់ដូចតាវ៉ាល់ មុនគេមិនសួរដូចមិនសួរ សម្លាប់ៗ សម្លាប់ត្រឹមនិរតីមកខ្ទាំង ។

ដានី ៈ និរតីមកខ្ទាំង?

មុត ៈ បាទ! ....(ស្តាប់មិនបាន) ខ្ទាំងដែរហើយ ចាប់ចេះតែចាប់ ក្រុមតាវ៉ាល់អត់ទេ ការលើករួចរឿងគេតាមដានចេះតាមដាន ក្រោយមកតាវ៉ាល់ស្រាប់តែឆាប់ដែរ រឿងយើងធ្វើការចេះធ្វើទៅមិនមានអ្នកណាចាក់ចុះស្អីៗទេ ។ និរតីមក បានខ្ទាំងវៃធូរ អត់ដឹងខុសត្រូវទេ ឲ្យតែជាប់ខ្សែខាងណាខាងណៃ ខ្ញុំភ័យ ខាងជាប់ខ្សែ ។ និរតីមកគេស្រាវជ្រាវរកខ្សែបាទ! វៃតាមខ្សែ ។

ដានី ៈ វៃតាមខ្សែ?

មុត ៈ លោកគ្រូអើយ វៃបាតណាបាតណៃ ។

ដានី ៈ និរតីមកក្មេងៗ ចាស់ៗ?

មុត ៈ ក្មេង យោធាគ្មានដឹងអីបានស្រួលទេ សុទ្ធតែចាប់ ។

ដានី ៈ អាយុប្រហែលប៉ុន្មានក្មេងៗ និរតី?

មុត ៈ មិនក្មេងប៉ុន្មានទេលោកគ្រូ កាលនោះសឹងយកអាយុខ្ញុំទៅប្រៀបវាមិនបាន ព្រោះក្មេងអាយុប្រហែល២០ៗដាង ២៥ ២៧វ៉ាវៗប៉ុននោះហើយយោធា ។

ដានី ៈ មានស្រី ហើយមានតែប្រុស?

មុត ៈ មានតែប្រុស ។

ដានី ៈ ចុះអ្នកគ្រប់គ្រងអីដូច?

មុត ៈ បើអ្នកគ្រប់គ្រងពួកនែក! ស្រីៗអត់មានកាំភ្លើងទេ បើប្រុសៗមាន ពួកយោធា ។

ដានី ៈ ស្រីៗមានមកគ្រប់គ្រងច្រើនដែរ?

មុត ៈ បើវាចុះគ្រប់ភូមិ គ្រប់មុខសញ្ញាចុះ អត់សួរឃើញចង្កោមគ្នាប៉ុន្មានទេ ឃើញ ៤-១០នាក់ ។

ដានី ៈ ៤-១០នាក់?

មុត ៈ បាទ! នឹងឃើញគេចុះតាមសហករណ៍ កាលនោះចុះមកវារកគ្នាបំបែកនៅតាម សហករណ៍នៅតាមខេត្ត នៅតាមមុខព្រួញ តិចៗទេ អត់មានផ្តុំគ្នាទេ ។

ដានី ៈ ចុះកាលនោះពូអត់ដឹង គណៈតំបន់ឈ្មោះអី បន្ទាប់ពីឈ្មោះ តាហ៊ីងៗ?

មុត ៈ កាលនោះដូចខ្ញុំវាឡើយឡាយដូចវាខ្ទឹៗពេក ដូចកាសែតចឹងឯង វាលឿន ពេលមិនបាននៅត្រាំត្រាយអីប៉ុន្មានៗ តាំងពីបាត់តាហ៊ីង មកក៏មិនទាន់ពូ ដំណឹងតែងតាំងថាអ្នកនេះឡើង អ្នកនោះឡើងៗ

ដានី ៈ ដែលពូឈ្មោះ ណេង?

មុត ៈ ណេង រាម ពូតើលោកគ្រូ ទាល់តែមិនដឹងថាគេមុខសញ្ញាខាងអី ពូៗ ក៏ប៉ុន្តែ ពូៗគ ពូដូចគេហៅ មិនមែនថាពូយើងបានធ្វើការរួមរស់ស្គាល់ណាពូៗ

ដានី ៈ គ្រាន់តែពូ?

មុត ៈ បាទ! ដូចថាការផ្សារគាត់ខាងអី ពូៗនឹងឯង ប៉ុន្តែពូដូចថាពូដូចយើងៗ

ដានី ៈ ចឹងពូថា ឈ្មោះបងយឿកអីនឹង ឥឡូវគាត់អាយុប៉ុន្មានឥឡូវ?

មុត ៈ បងយឿកសព្វថ្ងៃ ក្បែរ៦០ហើយៗ

ដានី ៈ អាយុច្រើនជាងពូ?

មុត ៈ ៦០ហើយ បងខ្ញុំៗ

ដានី ៈ ពូៗយឿក?

មុត ៈ អូ! ខ្ញុំនៅក្មេងជាងនឹង បាទ! បងយឿកៗ

ដានី ៈ គាត់អាច?

មុត ៈ បងយឿកច្បាស់ការណ៍ បើជួបបងយឿកស្អាតណាស់ ព្រោះគាត់យល់ន័យ នឹងច្រើនៗ

ដានី ៈ គាត់ទៅ បើយើងទៅពីនឹងទៅ.....(ស្តាប់មិនបាន)?

មុត ៈ ហួសពីទឹកថ្លាតិចៗ

ដានី ៈ ហួសទឹកថ្លាតិចជិតដែរ?

មុត ៈ បាទ! ពីដើមគេហៅសាលាអ៊ិនតាំចាស់ ទៅពីសាលាអ៊ិនតាំចាស់ផ្លូវចូលអញ្ច្រាញ គាត់នៅនឹងថ្នល់ៗ

ដានី ៈ ក្បែរសាលាអ៊ិនតាំចាស់?

មុត ៈ បាទៗ សួរតែអ្នកតាមថ្នល់ ភូមិគេនៅតាមថ្នល់សួររកផ្ទះបងយឿកៗ

ដានី ៈ ប្រពន្ធគាត់ឈ្មោះអី?

មុត ៈ ប្រពន្ធគាត់ខ្ញុំអត់ស្គាល់ ភ្លេចបែៗនេះៗ បងសួររកនោះថ្នល់ ផ្លូវត្រង់ទៅ អត់មានលំបាកកំបាំងទេ គាត់ទៅបានចាលលមកជួបៗ បានទៅដល់ផ្ទះ បងឯងឲ្យកូន ចាលលមកជួបហើយគាត់នៅធ្វើការអត្តការៗ

ដានី ៖ អូ!គាត់នៅធ្វើការអន្តការ?

មុត ៖ បាទ! ស្រុកក្រោម ។

ដានី ៖ លេខទូរស័ព្ទគាត់ប៉ុន្មាន?

មុត ៖ ទេ! រកមើលការតទូរស័ព្ទសិន ។

ដានី ៖ លោកពូចឹងពេលដែលលោកពូទៅចូលប៉ារ៉ាយ៉ាងម៉េចទៀតទៅ?

មុត ៖ ខ្ញុំចូលទៅប៉ារ៉ាកំសត់ណាស់ លោកគ្រូអើយ វេទនាអណ្តែតអណ្តូង ។

ដានី ៖ ប៉ារ៉ាខាងណា?

មុត ៖ ប៉ារ៉ាកាលនោះខ្ញុំធ្វើជាមួយលោក សឹន សានៗ កូនគាត់ឈ្មោះ សឹន សូប័រ ។ រួចលោក សឹន សាន គាត់ចូលមកស្រុកហើយ បានគាត់ស្លាប់ ។ ដល់បន្ទាប់មក ពួក សូ ចាន់ហេង ពួកលោកយូ ឈា ពួកអី សុទ្ធតែមេពួកគា លួតតាអីទៅព្រៃនោះ ។ កាលនោះខ្ញុំនៅក្មេងដែរ ខ្ញុំបានធ្វើទាហានៗរហូត ទាល់តែអ៊ុនគាក់ចូល ។

ដានី ៖ ពូនៅម្តុំណា?

មុត ៖ ខ្ញុំនៅមុនដំបូងនៅបន្ទាយអំពិល នៅបឹង៧ៗក្រោយទៀត បញ្ជូនវរៈ២១៩ ពីដើមមិញនៅវរៈ ២០៧ ។ចេញពីវរៈ២០៧ទៅ វរៈ២១៩ ទៅដំរំនង ចាន់ ។

ដានី ៖ ចឹងលោកពូចូលមកនៅស្រុកវិញ ជំនាន់អ៊ុនគាក់ចូលហើយ?

មុត ៖ អ៊ុនគាក់ចូល បាទ! វេទនាណាស់តាំងពីដំណើរឆាកជីវិតលោកគ្រូអើយ តាំងពីអាយុ១៦មក ១៧ បានបែកបាក់នៅ ។

ដានី ៖ ចុះពូបានមានតួនាទីអីដែល ពេលពូទៅធ្វើប៉ារ៉ាអី?

មុត ៖ ខ្ញុំបានកងអនុសេនាតូចដែរ ។

ដានី ៖ អនុសេនាតូច?

មុត ៖ អនុសេនាតូច សម័យយើងហៅ(និយាភាសាផ្សេង).......បើយើងនិយាយថាសព្វថ្ងៃថាកងអនុ សេនាធំ ។

ដានី ៖ ចុះពូរៀបការជាមួយមីងរៀបការពេលណា?

មុត ៖ ឆ្នាំ៨៧ ។

ដានី ៖ ៨៧?

មុត ៖ ៨៧ ៨៨នេះឯងលោកគ្រូ ។

ដានី ៖ រៀបការនៅណា?

មុត ៖  នៅជាយដែន ។

ដានី ៖  នៅជាយដែនណា?

មុត ៖  ជាយដែននៅជិរ៉េ ។

ដានី ៖  នៅជិរ៉េ?

មុត ៖  បាទ!

ដានី ៖  កាលនឹងមីងអ្នកស្រុកកំណើតនៅណា?

មុត ៖  នៅប៉ែក....(ស្ដាប់មិនបាន)  ស្រុកស្រីស្នំៗ ។

ដានី ៖  នៅស្រុកស្រីស្នំ  ខេត្តសៀមរាប?

មុត ៖  បាទ!

ដានី ៖  ខាងអីព្រៃ?

មុត ៖  ស្រុកព្រៃជ្រួយឆ្នួន ។

ដានី ៖  ព្រៃជើងជ្រួយឆ្នួន?

មុត ៖  ព្រៃជើងជ្រួយឆ្នួន  នៅក្នុងស្រុកស្រីស្នំ ។

ប្រពន្ធ ៖  ម្ខាងស៊ឹងនឹងៗអាងត្រពាំងថ្មនឹង ។

ដានី ៖  អូ!  ចឹង ។

មុត ៖  ស្រុកភ្នំស្រុក ។

ប្រពន្ធ ៖  ព្រំប្រទល់ជាប់គ្នា ។

មុត ៖  ម្ខាងស៊ឹងម្នាក់ ។

ដានី ៖  ស្រីស្នំមានព្រំប្រទល់ជាប់ភ្នំស្រុកដែរ  ជាប់ថ្មពួក  ស្វាយចេក?

មុត ៖  បាទៗ ។

ដានី ៖  ចឹងដល់ពេលពូ ដល់ពេលអ៊ុនតាក់  ពូចូលមកវិញ  ពូមានតួនាទីអីនៅក្នុង?

មុត ៖  ខ្ញុំនៅក្នុងអ៊ុនតាក់  មាតុភូមិនិវត្តន៍មក  ខ្ញុំនឹកឃើញថាខ្ញុំអត់មានស្រែអត់មានភ្លឺ  អត់មានអីផង ក៏នាំកូននាំចៅសម្រេចថាមករកបងរកប្អូននៅស្រុកកំណើតនេះ  អត់មានអីប្រើប្រាស់ទេ  ចាំមក នេះ  មករកស្រុកកំណើតនេះចាំទទួលខ្វាចបាន  បងប្អូនបានរទេះគោជីកអុសជីកអីនោះ  ព្រោះ យើងអត់មានអីនោះ ។  ខ្ញុំក៏សុំលាលែងគេមកតាមគេបណ្ដោយ  ខ្ញុំក៏សុំច្បាប់គេលាលែងពីការ ងារនោះ  ឈប់ផ្អាកមកពីការងាររដ្ឋការ  ក៏បែកបាក់គ្នារហូត  កាន់តែវ័យផង  សព្វថ្ងៃឈប់ទៅ ណាទៅណែនៅផ្ទះរកស៊ីធម្មតា ។

ដានី ៖ ប៉ុន្តែកាលមកដំបូងមានតួនាទីដែរ?

មុត ៖ បាទ! កាលដែលនៅឯព្រៃមានតួនាទីដែរ ។

ដានី ៖ ប៉ុន្តែយើងចូលស្រុកដំបូង មកដល់ចូលស្រុកមកយើងមកនេះបណ្តោយ?

មុត ៖ បាទ! អត់មានតួនាទីអីទេ ហើយការងារជាទាហានគេនៅតែហៅទៅ តែខ្ញុំ អត់ទៅ ។

ដានី ៖ អត់ទៅ?

មុត ៖ បាទ! ខ្ញុំអត់ទៅ ប្រពន្ធកូនវាយ៉ាប់វាក្រ អត់មានអីហូប អត់មានបន(កន្លែង)ទីតាំង អត់មានទីពឹងអី ។ បាទ!ខ្ញុំមកនៅស្រុកកំណើត បានរកស៊ីតិតុក ក៏លែងចង់ទៅហើយ....(ស្តាប់មិនបាន) ។

ដានី ៖ ពូខ្ញុំដូចជាអស់សំនួរត្រូវសួរនាំពូទៀតហើយ ចឹងពូមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំអត់បានសួរនាំពូ ទៀត?

មុត ៖ បាទ! នៅលោកគ្រូ ខ្ញុំដូចជាអស់ដែរ រឿងដែលបញ្ចប់ គឺបញ្ចប់ត្រឹមបែក បាក់គ្នាចូលព្រៃមុខបញ្ចប់ដែលវៀតណាមចូលមកដល់ក្រឡាញ់ ក៏យាយថែម ក៏បែកខ្ញុំក៏រត់ដែរ រត់ទាំងយាយថែម រត់ទាំងខ្ញុំដែរ ។ ក៏ប៉ុន្តែ ២នាក់នេះ ដោយសារយាយថែមការងារគាត់ផ្សេង ខ្ញុំផ្សេង ។ បាទ! បែកបាក់គ្នា ព្រោងប្រៀបក៏ បើរឿងថាអស់ស្តេច វាចប់ត្រឹមនេះហើយ វាចប់ត្រឹមដែលបែកបាក់គ្នា អត់មានបន្តវេណណាកាន់ការអីទៀតទេ ចប់ ។

ដានី ៖ បាទ! ចឹងខ្ញុំអរគុណពូច្រើន ដែលលោកពូចំណាយពេលផ្តល់បទសម្ភាសន៍ជា មួយខ្ញុំនេះប្រហែលជាជិត២ម៉ោង ។ បាទ! អរគុណច្រើនលោកពូ ។

មុត ៖ បាទ!

«ចប់»